


# គុកធំ -ចង្អៀតខ្លាំង: ភាពចង្អៀតណែនរបស់អ្នកទោស នៅកម្ពុជា និងក្តីស្រមៃនៃមណ្ឌលអប់រំកែប្រែទី ៤

របាយការណ៍សង្ខេបលីកាដូ
ខែកក្កដា ២០១០

លីកាដូ
LICADHO

សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

**LICADHO**

Cambodian League for the
Promotion and Defense of Human Rights

# គុកធំ-ចង្អៀតខ្លាំង: ភាពចង្អៀតណែនរបស់អ្នកទោសនៅកម្ពុជា និងក្តីស្រមៃនៃមណ្ឌលអប់រំកែប្រែទី៤

របាយការណ៍សង្ខេបលីកាដូ

ខែកក្កដា ឆ្នាំ២០១០


សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

## សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការស្ថិតនៅជួរមុខគេក្នុងកិច្ចការពារសិទ្ធិមនុស្សនៅកម្ពុជា និងលើកស្ទួយការគោរពសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយតាមរយៈរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័ននានា។ ការកសាងសមិទ្ធិផលរបស់ខ្លួនក្នុងអតីតកាល **លីកាដូ** បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងឃ្លាំមើលរដ្ឋាភិបាលតាមរយៈ កម្មវិធីសិទ្ធិមនុស្សនានាពីការិយាល័យកណ្តាលរបស់ខ្លួននៅភ្នំពេញ និងនៅតាមសាខាទូទាំង ១២ ខេត្ត-ក្រុងផ្សេងទៀត។

**អង្គការលីកាដូ អនុវត្តសកម្មភាពរបស់ខ្លួនតាមរយៈកម្មវិធីធំៗពីរ :**

**កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស:**

- **ឃ្លាំមើលការរំលោភសិទ្ធិមនុស្សដែលប្រព្រឹត្តដោយបុគ្គលរបស់រដ្ឋ លើការរំលោភសិទ្ធិស្ត្រី និងការរំលោភសិទ្ធិកុមារ:** បុគ្គលិកធ្វើការស៊ើបអង្កេតលើករណីរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្តដោយបុគ្គលរបស់រដ្ឋ ចំពោះការរំលោភបំពានលើស្ត្រី និងកុមារ ហើយជនរងគ្រោះត្រូវបានផ្តល់សេវាជួយជ្រោមជ្រែងតាមរយៈការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន។
- **ការប្រឹក្សាផ្នែកច្បាប់ និងកិច្ចការពារផ្នែកច្បាប់:** ជនរងគ្រោះត្រូវបានផ្តល់ជូននូវការ ប្រឹក្សាផ្នែកច្បាប់ ហើយចំពោះករណីសំខាន់ៗទទួលបាននូវកិច្ចការពារផ្នែកច្បាប់ ដែលផ្តល់ជូនដោយក្រុមអ្នកប្រឹក្សាផ្នែកច្បាប់ និងក្រុមមេធាវីការពារសិទ្ធិមនុស្ស។
- **ការឃ្លាំមើលពន្ធនាគារ:** អ្នកស្រាវជ្រាវពន្ធនាគារធ្វើការឃ្លាំមើលពន្ធនាគារចំនួន ១៨ ដើម្បីធ្វើការវាយតម្លៃអំពីស្ថានភាពនៅក្នុងពន្ធនាគារ និងដើម្បីធានាថាពិរុទ្ធជនទទួលបាននូវតំណាងផ្នែកច្បាប់។
- **ជំនួយផ្នែកវិជ្ជសាស្ត្រ:** ក្រុមគ្រូពេទ្យផ្តល់សេវាវិជ្ជសាស្ត្រដល់អ្នកទោស និងមន្ត្រីពន្ធនាគារចំនួន ១២ កន្លែង។ បន្ថែមពីលើនេះ ក៏ជួយផ្តល់សេវាវេជ្ជសាស្ត្រ និងបញ្ជូនជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្សទៅកាន់មន្ទីរពេទ្យ។

**កម្មវិធីទំនាក់ទំនង និងការទាក់ទាញមតិគាំទ្រ:**

- **ការហ្វឹកហ្វឺនសហគមន៍ អប់រំ និងការតស៊ូមតិ:** អ្នកហ្វឹកហ្វឺន និងអ្នកតស៊ូមតិធ្វើការអប់រំដល់សាធារណៈជន អំពីសិទ្ធិស្ត្រី និងសិទ្ធិកុមារ បង្កើតបណ្តាញការពារនៅតាមមូលដ្ឋាន និងធ្វើការតស៊ូមតិ ដើម្បីឱ្យមានការផ្លាស់ប្តូរសង្គម និងច្បាប់។
- **ការតស៊ូមតិជាសាធារណៈ និងតាមសហគមន៍:** ករណីរំលោភសិទ្ធិមនុស្សដែលស៊ើបអង្កេត ដោយលីកាដូ ត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធទិន្នន័យដើម្បីឱ្យមានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មានវិភាគផលិតជារបាយការណ៍ជាប្រចាំ ( ការបោះពុម្ពជារបាយការណ៍ និងរបាយការណ៍សោតទស្សន៍)។

**ចំពោះព័ត៌មានបន្ថែមសូមទាក់ទង៖**

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធានអង្គការលីកាដូ

អាសយដ្ឋាន៖ អង្គការលីកាដូ (សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស)

ផ្ទះលេខ ១៦ ផ្លូវលេខ ៩៩ រាជធានីភ្នំពេញ កម្ពុជា

ទូរស័ព្ទ៖ (៨៥៥) ២៣ ៧២៧ ១០២ / ៣៦៤ ៩០១ ទូរសារ៖ (៨៥៥) ២៣ ៧២៧ ១០២ / ២១៧ ៦២៦

អ៊ីម៉ែល៖ contact@licadho-cambodia.org  គេហទំព័រ៖ http://www.licadho-cambodia.org/

# មាតិកា


**បុព្វកថា** ~~~~~~~~~~~~~~~~~~~~ **១**

ពន្ធនាគារទាំង១៨ ដែលឃ្លាំមើលដោយអង្គការលីកាដូ ( អត្រាតួលេខឃុំឃាំង) ------------------- ២

**១. ប្រវត្តិ មណ្ឌលអប់រំកែប្រែទី៤** ~~~~~~~~~~~~~~~~~~~~ **៤**

**២.មណ្ឌលអប់រំកែប្រែទី៤ និងការកាត់បន្ថយភាពចង្អៀតខ្លាំង** ~~~~~~~~~~~~~~~~~~~~ **៦**

លទ្ធភាពផ្ទុកអ្នកទោសនៃពន្ធនាគារ ពុំមែនជាបញ្ហាតែមួយគត់ទេ ------------------- ៦

លទ្ធភាពផ្ទុកនៅពន្ធនាគារកម្ពុជា ------------------- ៧

អត្រាខ្ពស់ខ្លាំងនៃកំណើនអ្នកទោស ------------------- ៨

អត្រាអ្នកទោសនៅក្នុងប្រទេសកម្ពុជាក្នុង ១00,000នាក់ ------------------- ១០

កត្តារួមផ្សំបណ្តាលអោយមានបញ្ហាចង្អៀតខ្លាំង -------------------១៣

ជម្រើសផ្សេងៗក្រៅពីការឃុំខ្លួនក្នុងពន្ធនាគារ : អាចធ្វើទៅបាន មានប្រសិទ្ធិភាព និងមានលក្ខណមនុស្សធម៌ផង ---- ១៤

អនុសាសន៍ ------------------- ១៩

**៣. មណ្ឌលអប់រំកែប្រែទី ៤ និង ការបណ្តុះបណ្តាលវិជ្ជាជីវៈ** ~~~~~~~~~~~~~~~~~~~~ **២១**

តម្លាភាពៈ -------------------២១

ការប្រើពលកម្មអ្នកទោស ជាប្រយោជន៏ឯកជន -------------------២២

ប្រាក់ឈ្នួលអ្នកទោស------------------- ២៤

ការជ្រើសរើសកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈសមរម្យ ------------------- ២៤

**៤. ការប្រមូលផ្តុំអ្នកទោស ទៅមណ្ឌលអប់រំកែប្រែថ្នាក់ជាតិ** ~~~~~~~~~~~~~~~~~~~~ **២៦**

## បុព្វកថា

អ្នកទោសនៅក្នុងពន្ធនាគារកម្ពុជា មានការកើនឡើងយ៉ាងខ្លាំងដែលមិនធ្លាប់មានពីមុនមក។ ត្រឹមតែពី ៦ ឆ្នាំ កន្លងមកនេះពន្ធនាគារទាំង ១៨ ដែលលីកាដូបានឃ្លាំមើល គឺដល់កម្រិតមួយរយភាគរយនៃសមត្ថភាពរួមរបស់ពន្ធនាគារទាំងនោះទៅហើយ[១]។ ចាប់តាំងពីពេលនោះមក អាត្រាអ្នកទោសក្នុងពន្ធនាគារមានកំណើនឡើង ដែលកំណើនក្នុងកម្រិតជាមធ្យមប្រមាណ១៤% ក្នុងមួយឆ្នាំ។ ស្របពេលជាមួយគ្នានេះ អគារឃុំឃាំងនៃពន្ធនាគារក៏ត្រូវបានពង្រីកផងដែរ ប៉ុន្តែទោះជាយ៉ាងណា វាមិនទាន់មានល្បឿនលឿនសមល្មមទៅនឹងអត្រាកើនឡើងយ៉ាងខ្ពស់នៃចំនួនអ្នកទោសទេ។

អគ្គនាយកពន្ធនាគារ បាននរាយការណ៍កាលពីខែមីនា ឆ្នាំ២០១០ កន្លងទៅនេះថា ពន្ធនាគារទាំងអស់នៅកម្ពុជា កំពុងឃុំឃាំងអ្នកទោសសរុប ១៣,៣២៥ នាក់ ស្មើនឹង ១៦៧% នៃសមត្ថភាពពន្ធនាគារដែលអាចដាក់បានត្រឹមតែ ៨,០០០ នាក់ ប៉ុណ្ណោះ យោងរបាយការណ៍ខែមិថុនា ឆ្នាំ២០១០ កន្លងទៅនេះ ក្នុងពន្ធនាគារទាំង ១៨ ដែលអង្គការលីកាដូកំពុងឃ្លាំមើលពេលបច្ចុប្បន្ន។ ពន្ធនាគារនីមួយៗឃុំឃាំងអ្នកទោសរហូតដល់ ១៧៥% នៃសមត្ថភាពរបស់ខ្លួន។ ដែលក្នុងនោះ មួយភាគបីនៃអ្នកទោសកម្ពុជាចំនួនប្រមាណ ៤,០០០ នាក់ ជាពិរុទ្ធជនដែលស្ថិតក្នុងការឃុំឃាំងបណ្តោះអាសន្ន រងចាំសវនាការ។

រហូតមកដល់ពេលនេះ ដំណោះស្រាយតែមួយគត់របស់រាជរដ្ឋាភិបាលចំពោះវិបត្តិចង្អៀតណែននៃពន្ធនាគារនេះគឺ ការកសាងពន្ធនាគារបន្ថែម និងពង្រីកសមត្ថភាពអគារឃុំឃាំងនៃពន្ធនាគារដែលមានស្រាប់[២]។ កិច្ចខិតខំប្រឹងប្រែងថ្មីៗរបស់អគ្គនាយកដ្ឋានពន្ធនាគារ គឺការកសាងមណ្ឌលអប់រំកែប្រែទី៤ (ម៤)។ ពន្ធនាគារថ្មីនេះស្ថិតនៅក្នុងខេត្តពោធិ៍សាត់ បានបើកឱ្យដំណើរការ កាលពីខែមករា ឆ្នាំ២០១០ កន្លងទៅនេះ ហើយត្រូវបានគ្រោងឡើងដើម្បីដាក់អ្នកទោស ២,៥០០ នាក់។

ការកសាងត្រឹមតែអាគារឃុំឃាំងថ្មី គឺមិនអាចលុបបំបាត់ភាពចង្អៀតណែនខ្លាំងនេះបានទេ។ ប្រសិនបើចំនួនអ្នកទោសនៅក្នុងពន្ធនាគារកម្ពុជានៅតែមានការកើនឡើងយ៉ាងគំហុក។ ពន្ធនាគារដែលទើបតែនឹងកសាងត្រូវបានប្រើប្រាស់ស្មើនឹងសមត្ថភាពផ្ទុក ឬ លើសម្តងហើយម្តងទៀត ក្នុងខណៈដែលពន្ធនាគារចាស់ៗនៅតែបន្តហូរចូល

[១] តួលេខខាងលើ ផ្អែកទៅលើការផ្តល់ព័ត៌មានដោយអ្នកស្រាវជ្រាវពន្ធនាគារទាំង ១៨ កន្លែង លើកលែងតែតួលេខណា ដែលមានបញ្ជាក់ក្រៅពីនេះ។ ពន្ធនាគារទាំង ១៨ នេះ អាចតំណាងឱ្យអ្នកទោសប្រមាណ ៩០% នៃអ្នកទោសកម្ពុជាទាំងអស់។

[២] បញ្ហានេះ អាចកើតឡើងមួយផ្នែកអាស្រ័យដោយកង្វះវិធានការផ្សេងពីការដាក់ទណ្ឌកម្មដោយឃុំឃាំងក្នុងពន្ធនាគារ ដែលទើបតែថ្មីៗនេះ ត្រូវបានកែប្រែនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌថ្មី។ សូមអានភាគទី២។ ប៉ុន្តែ ក្រមព្រហ្មទណ្ឌអន្តរកាលក៏បានចែងនូវជម្រើស២ដែរក្រៅពីការដាក់ពន្ធនាគារនេះគឺៈ ទណ្ឌកម្មដោយការព្យួរទោស (ក្រមព្រហ្មទណ្ឌអន្តរកាល មាត្រា ៧០) និងការដោះលែងដោយមានលក្ខខណ្ឌ (ក្រមពហ្មទណ្ឌអន្តរកាល មាត្រា ៧១)។ ទាំងពីរមាត្រានេះ ជាមួយនឹងវិធានការដោះលែងមុនពេលកាត់ក្តី គឺកម្រត្រូវបានប្រើប្រាស់ណាស់។

នូវចំនួនអ្នកទោសលើសចំណុះឥតដាច់។ ជាមួយគ្នានេះ មណ្ឌលអប់រំកែប្រែទី៤ គឺពុំអាចនឹងដោះស្រាយបញ្ហាចង្អៀតណែននេះបានទេ ដូច្នេះការរិះរកវិធីដោះស្រាយផ្សេងពីនេះទៀត គឺជាការចាំបាច់។ របាយការណ៍សង្ខេបនេះ នឹងបង្ហាញនូវវិធីសាស្ត្រផ្សេងៗមួយចំនួន ដែលសង្ឃឹមថានឹងអាចដោះស្រាយបញ្ហាខាងលើនេះបាន។

មូលហេតុនៃការបង្កើតអោយមានមណ្ឌលអប់រំកែប្រែទី៤ នេះ គឺមិនមែនត្រឹមតែដើម្បីបង្កើនសមត្ថភាពពន្ធនាគារដើម្បីកាត់បន្ថយភាពចង្អៀតពីបណ្តាពន្ធនាគារផ្សេងៗនោះទេ។ លើសពីនេះអគ្គនាយកដ្ឋានពន្ធនាគារ មានផែនការប្រែក្លាយទីនោះឱ្យទៅជាពន្ធនាគារកសិកម្មមួយយ៉ាងធំ។ ដូច្នេះកិច្ចខិតខំប្រឹងប្រែងឱ្យមានមណ្ឌលអប់រំកែប្រែទី៤ នេះឡើង អាចសបញ្ជាក់ឱ្យឃើញនូវការផ្លាស់ប្តូរមួយរបស់កម្ពុជាក្នុងការឈានឆ្ពោះទៅរកប្រព័ន្ធពន្ធនាគារដែលយកកិច្ចការស្តារនីតិសម្បទាផ្តោតលើការធ្វើការងាររបស់អ្នកទោសជាឧបករណ៍ដើម្បីកែប្រែ។

ការស្តារនីតិសម្បទារបស់អ្នកទោស ជាការផ្លាស់ប្តូរយ៉ាងសំខាន់ និងវិជ្ជមានមួយនៅក្នុងគោលនយោបាយយុត្តិធម៌ និងព្រហ្មទណ្ឌនៅកម្ពុជា។

**ពន្ធនាគារទាំង១៨ ដែលឃ្លាំមើលដោយអង្គការលីកាដូ ( អត្រាតួលេខឃុំឃាំង)**




ជាគោលការណ៍ លីកាដូ សូមគាំទ្រចំពោះសកម្មភាពអប់រំ និងកែប្រែដោយហេតុថាការស្តារនីតិសម្បទាគឺជានិច្ចកាល ជាផ្នែកមួយយ៉ាងសំខាន់នៅក្នុងគ្រប់ប្រព័ន្ធព្រហ្មទណ្ឌទាំងអស់។ ប៉ុន្តែ គន្លឹះសំខាន់ដែលនាំឱ្យកម្មវិធីស្តារនីតិសម្បទានេះដំណើរការទៅបានដោយជោគជ័យ គឺអាស្រ័យទៅលើការមានគម្រោងការងារលំអិត និងការ

អនុវត្តន៍ជាក់ស្តែង។ មកដល់ចំណុចនេះ របាយការណ៍សង្ខេបនេះ ក៏បានរកឃើញនូវការព្រួយបារម្ភផងដែរ ដោយហេតុថា កម្ពុជាកំពុងពង្រីកនូវការធ្វើការងាររបស់អ្នកទោសនៅមណ្ឌលអប់រំកែប្រែទី៤ និងនៅពន្ធនាគារផ្សេងទៀត។

# ១. ប្រវត្តិ មណ្ឌលអប់រំកែប្រែទី៤

អគ្គនាយកដ្ឋានពន្ធនាគារ នៃក្រសួងមហាផ្ទៃបានធ្វើការសិក្សាអំពីគម្រោងកសាងពន្ធនាគារកសិកម្មនៅ ខេត្តពោធិ៍សាត់ ដែលត្រូវចំណាយពេលយ៉ាងឆាប់ក៏ពីរឆ្នាំដែរ ។ ពិធីបញ្ចុះបឋមសិលាបានប្រព្រឹត្តទៅកាលពីខែសីហា ឆ្នាំ២០០៩ កន្លងទៅ ហើយពន្ធនាគារនេះចាប់ផ្តើមដំណើរការដំបូងបង្អស់នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១០ ហើយក៏ជាថ្ងៃលើកដំបូងនៃការមានវត្តមានអ្នកទោសបានមកដល់ទីនោះ ។



*បង្គោលព្រំផ្លូវ ចូលទៅមណ្ឌលអប់រំកែប្រែទី៤ ។ ពន្ធនាគារនេះមានផ្ទៃដីសរុប៨៤៦ ហិកតា ដែលផ្នែកខ្លះជាដីព្រៃ ។ ផ្នែកខ្លះនៃដីនោះនឹងប្រើសម្រាប់ធ្វើកសិកម្ម*

មណ្ឌលអប់រំកែប្រែទី៤ គឺជាពន្ធនាគារស៊ីវិលទី២៥ របស់កម្ពុជា និងជាពន្ធនាគារថ្នាក់ជាតិទី៤ ។ មណ្ឌលនេះ នឹងក្លាយទៅជាស្ថាប័នកែប្រែធំជាងគេបំផុតនៅក្នុងប្រទេស ។ មណ្ឌលនេះមានផ្ទៃដីសរុបទំហំ ៨៤៦ ហិកតា[៣] ដែលផ្នែកខ្លះគឺជាដីព្រៃ ហើយមកដល់ត្រឹមខែមិថុនា ឆ្នាំ២០១០ មណ្ឌលនេះបានទទួលអ្នកទោសចំនួន១៥៤នាក់ ឃុំឃាំងនៅក្នុងអគារឈើចំនួនពីរ ។ រាជរដ្ឋាភិបាលមានគម្រោងកសាងអគារដាច់ៗពីគ្នាចំនួន ៥ ដែលគេហៅថា "សាខា" នៅលើដីនោះ ដែលអគារនីមួយៗមានសមត្ថភាពដាក់អ្នកទោសបានចំនួន ៥០០នាក់ ។ តាមប្រភពព័ត៌មានបានឱ្យដឹងថា អគារមួយក្នុងចំណោមអគារទាំងប្រាំនេះនឹងទុកសម្រាប់ដាក់អ្នកទោសអនីតិជន ។ ការងារសាងសង់ទាំងអស់ត្រូវបានធ្វើឡើងដោយកំលាំងអ្នកទោស ។ រាជរដ្ឋាភិបាល មិនទាន់បានបង្ហើបឱ្យដឹងអំពីពេលវេលាដែលត្រូវបញ្ចប់ការសាងសង់នៅឡើយទេ ។

មួយផ្នែកធំនៃដីពន្ធនាគារនេះ ត្រូវប្រើប្រាស់ជាដីកសិកម្ម ដែលតាមមើលទៅ គឺប្រើកម្លាំងពលកម្មអ្នកទោសទាំងអស់ ។ តាមមន្ត្រីរដ្ឋាភិបាលបានរាយការណ៍ឱ្យដឹងថា ដំណាំដែលត្រូវដាំទាំងនោះរួមមាន អំពៅ កៅស៊ូ ពោត សណ្តែក ដំឡូងមី និងល្ង ជាដើម[៤] ។ តាមកាសែតភ្នំពេញប៉ុស្តិ៍បានរាយការណ៍ថា ផលិតកម្មកសិកម្មចាប់ផ្តើម

---

[៣] ដីសម្បទានដំបូងជិត ១,០០០ ហិកតា ប៉ុន្តែដី ទំហំ ២០០ ហិកតា ប៉ះចំលើដីស្រែចម្ការរបស់ប្រជាពលរដ្ឋជាង ១០០គ្រួសារ ដែលនៅជិតពន្ធនាគារនោះ ។ អគ្គនាយកដ្ឋានពន្ធនាគារអះអាងថាបានកាត់បន្ថយទំហំដីរបស់ខ្លួនមកនៅត្រឹម ៨៤៦ ហិកតាវិញ ។ ប៉ុន្តែយ៉ាងហោចណាស់មាន ២៧គ្រួសារ នៃភូមិពីរក្នុងខេតពោធិ៍សាត់ បានអះអាងថាមន្ត្រីពន្ធនាគារបានរំលោភលើដីចំម្ការជាង ៨៧,៥ ហិកតា ។ សូមអានកាសែតភ្នំពេញប៉ុស្តិ៍ ដែលមានចំណងជើងថា "ពន្ធនាគារ ត្រូវចោទប្រកាន់រំលោភដីធ្លី" និពន្ធដោយលោក ម៉ៃ ទិត្ថារ៉ា ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១០ ទំព័រទី៤

នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១០ ដោយមានការភ្ជួររាស់ដីទំហំ ១២ ហិកតា[៥] ។

អគ្គនាយកដ្ឋានពន្ធនាគារ បានកំណត់នូវគោលដៅធំៗចំនួន៣ នៅក្នុងការកសាងមណ្ឌលអប់រំកែប្រែទី៤ នេះ ទី១ ដើម្បីកាត់បន្ថយភាពចង្អៀតណែនខ្លាំងនៅតាមបណ្តាពន្ធនាគារនានា។ ទី២ បង្កើតអោយមានការបណ្តុះបណ្តាលវិជ្ជាជីវៈ ទៅលើអ្នកទោស ដោយសង្ឃឹមថាកម្មវិធីនេះនឹងផ្តល់ឱកាសឱ្យអ្នកទោសរៀបចំខ្លួនឱ្យបានល្អជាងមុនក្នុងការចូលទៅរស់នៅក្នុងសង្គមវិញនៅពេលអនុវត្តទោសចប់ និងទី៣ ដើម្បីចំណាត់ថ្នាក់ទណ្ឌិតដែលជាប់ទោសរយៈពេលវែង ត្រូវឃុំឃាំងនៅមណ្ឌលអប់រំកែប្រែថ្នាក់ជាតិទាំងអស់រួមមាន: មណ្ឌលអប់រំកែប្រែ (ទី១ ទី២ ទី៣ និងទី៤) ធ្វើដូច្នេះ ដើម្បីឱ្យពន្ធនាគារតាមបណ្តាខេត្តនានា មានឱកាសឃុំឃាំងតែពិរុទ្ធជនដែលមិនទាន់បានកាត់ក្តីនៅឡើយ[៦] ។

នៅខណៈពន្ធនាគារដែលមានវ័យចំណាស់ និងទ្រុឌទ្រោមនៅកម្ពុជាមួយចំនួនកំពុងត្រូវការកសាងអគារថ្មី ឬជំនួសដោយការរើទីតាំង អង្គការលីកាដូមានការព្រួយបារម្ភអំពីការអនុវត្តន៏លើកិច្ចការស្តារលទ្ធភាពពលកម្មរបស់មណ្ឌលអប់រំកែប្រែទី៤ ដើម្បីអោយស្របទៅនឹងគោលដៅរបស់អគ្គនាយកដ្ឋានពន្ធនាគារ ដែលការស្តារលទ្ធភាពពលកម្មនេះ គឺជាទិសដៅដ៏សំខាន់នៃប្រព័ន្ធយុត្តិធម៌ និងព្រហ្មទណ្ឌ។

យើងជឿជាក់ថា នេះជាពេលវេលាសមរម្យដែលត្រូវលើកឡើងនូវក្តីកង្វល់ទាំងនេះ មុនពេលដែលគម្រោងនេះត្រូវបានបញ្ចប់ ដូច្នេះព័ត៌មានលំអិតអំពីការកសាងមណ្ឌលអប់រំកែប្រែទី៤ គួរណាស់ត្រូវមានការបង្ហាញជាសាធារណៈ ដល់ស្ថាប័នផ្សេងៗ ដូចជា រាជរដ្ឋាភិបាល សង្គមស៊ីវិល និងសាធារណៈជនទូទៅ។

---

[៤] សូមអានកាសែតភ្នំពេញប៉ុស្តិ៍ ដែលមានចំណងជើងថា "ការបណ្តុះបណ្តាលការងាររបស់អ្នកទោសបានចាប់ផ្តើម" និពន្ធដោយលោម ម៉ៃ ទិត្ថារ៉ា ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១០ ទំព័រទី១ និងព័ត៌មានបន្ថែមដែលទទួលបានពីអង្គការលីកាដូ ដែលបានសម្ភាសន៍ជាមួយមន្ត្រីពន្ធនាគារ។

[៥] អត្ថបទដដែល។

[៦] សូមអាន "របាយការណ៍ប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋានពន្ធនាគារ ឆ្នាំ២០០៧ និងទិសដៅឆ្នាំ២០០៨" ។ របាយការណ៍ប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋានពន្ធនាគារ ឆ្នាំ២០០៧: ក្រសួងមហាផ្ទៃ ថ្ងៃទី៤-៥ ខែកុម្ភៈ ឆ្នាំ២០០៨ ចំណងជើងថា "ក្របខណ្ឌគោលនយោបាយ សម្រាប់កំណែទម្រង់ពន្ធនាគារ" ថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៨ ទំព័រទី៣ និងបទបង្ហាញ ទំព័រទី១២។ សូមអានផងដែរនូវរបាយការណ៍ រីកចំរើនរបស់អគ្គនាយកដ្ឋានពន្ធនាគារ និងការលំបាកក្នុងការគ្រប់គ្រង ពន្ធនាគារក្នុងរយៈពេល៦ខែ ដំបូងនៃឆ្នាំ២០០៩" របាយការណ៍ស្តីពីការរីកចំរើនរបស់ អគ្គនាយកដ្ឋានពន្ធនាគារ ខែកញ្ញា ឆ្នាំ២០០៩ ទំព័រទី៦។

## ២‐មណ្ឌលអប់រំកែប្រែទី៤ និងការកាត់បន្ថយភាពចង្អៀតខ្លាំង

### លទ្ធភាពផ្ទុកអ្នកទោសនៃពន្ធនាគារ ពុំមែនជាបញ្ហាតែមួយគត់ទេ

ប្រព័ន្ធពន្ធនាគារកម្ពុជា ទទួលរងនូវភាពពិបាកយ៉ាងធ្ងន់ធ្ងរពីបញ្ហាចង្អៀតណែនខ្លាំង និងអគារចាស់ទ្រុឌទ្រោម។ អគ្គនាយកដ្ឋានពន្ធនាគារ បានរាយការណ៍កាលពីខែមីនា ឆ្នាំ២០១០ កន្លងទៅនេះថា ប្រព័ន្ធពន្ធនាគារទាំងមូលកំពុងឃុំឃាំងអ្នកទោសសុបទាំងអស់ ១៣,៣២៥ នាក់ ស្មើនឹង ១៦៧% នៃលទ្ធភាពផ្ទុកអ្នកទោសនៃពន្ធនាគារសរុបដែលអាចដាក់បានត្រឹមតែ ៨,០០០នាក់ ប៉ុណ្ណោះ។ ពន្ធនាគារទាំង១៨ ដែលលីកាដូបានឃ្លាំមើលក្នុងពេលបច្ចុប្បន្ននេះ មានអ្នកទោស សរុបចំនួន ១២,៦៤៦ នាក់ គិតត្រឹមខែមិថុនា ឆ្នាំ២០១០ កន្លងទៅនេះ ដែលស្មើនឹង ១៧៥% នៃលទ្ធភាពផ្ទុកអ្នកទោសនៃពន្ធនាគារ[៧]។ មកដល់ត្រឹម ខែធ្នូ ឆ្នាំ២០០៩ មួយភាគបីនៃអ្នកទោសទាំងនេះ គឺជាពិរុទ្ធជន។ អគារពន្ធនាគារមួយចំនួនត្រូវបានកសាងឡើងតាំងពីទសវត្សរ៍ ១៩០០ មកម្ល៉េះ ដែលភាពចាស់ទ្រុឌទ្រោមនៃអគារឃុំឃាំងគឺជាការព្រួយបារម្ភ លើសុវត្ថិភាពស្នាក់នៅរបស់អ្នកទោស និងសន្តិសុខពន្ធនាគារ[៨]។



*បន្ទប់អគារនៃមណ្ឌលអប់រំកែប្រែទី៤*

ច្បាស់ណាស់ រាជរដ្ឋាភិបាលត្រូវតែដោះស្រាយបញ្ហាប្រឈមទាំងពីរនេះ គឺភាពចង្អៀតណែន និងអគារទ្រុឌទ្រោម។ ប៉ុន្តែបើគ្រាន់តែដោះស្រាយបញ្ហាតាមរយៈការសាងសង់ពន្ធនាគារបន្ថែមតែមួយមុខគត់នោះ គឺជាយុទ្ធសាស្ត្រដែលពិបាកនឹងទទួលជោគជ័យណាស់។ ប្រវត្តិសាស្ត្របានបង្ហាញឱ្យឃើញម្តងហើយម្តងទៀតថា ការប្រើប្រាស់ប្រព័ន្ធពន្ធនាគារតែមួយមុខ គឺមិនអាចចៀសផុតពីវិបត្តិចង្អៀតណែនខ្លាំងបានទេ។

---

[៧] ប្រើប្រាស់តួលេខ ១៧៥% ពន្ធនាគារកម្ពុជាត្រូវស្ថិតនៅក្នុងចំណោម ២៥ ពន្ធនាគារដែលចង្អៀតជាងគេបំផុតនៅលើពិភពលោក យោងតាមទិន្នន័យដែលចងក្រងដោយសកលវិទ្យាល័យអន្តរជាតិសម្រាប់ការសិក្សាពន្ធនាគារ។ តាមការសិក្សាប្រទេសកម្ពុជាស្ថិតក្នុងចំណាត់ថ្នាក់ទី៤២ ប៉ុន្តែប្រើប្រាស់តួលេខចាប់ពីខែកក្កដា ឆ្នាំ២០០៩ លើគ្រប់ពន្ធនាគារទូទាំងប្រទេស និងប្រើប្រាស់តួលេខសរុបដែលមានការកើនឡើងតិចតួច។ ព័ត៌មានលំអិត សូមមើលនៅក្នុងសកលវិទ្យាល័យឃីង នៃមជ្ឈមណ្ឌលទីក្រុងឡុងដ៏អន្តរជាតិសម្រាប់ការសិក្សាពន្ធនាគារ" ពិភពលោកទាំងមូល-អត្រាឃុំឃាំង" ព័ត៌មានលំអិត សូមមើលនៅក្នុងគេហទំព័រ:
http://www.kcl.ac.uk/depsta/law/research/icps/worldbrief/wpb_stats.php?area=all&category=wb_0ccupancy ។

[៨] សម្រាប់ព័ត៌មានបន្ថែមទាក់ទងនឹងស្ថានភាពពន្ធនាគារនៅកម្ពុជា សូមអានរបាយការណ៍លីកាដូ: ស្ថានភាពពន្ធនាគារនៅកម្ពុជា ឆ្នាំ២០០៥-២០០៦ និងរបាយការណ៍លីកាដូ: ស្ថានភាពពន្ធនាគារ ឆ្នាំ២០០៤។ ចាប់តាំងពីរបាយការណ៍ទាំងនេះចេញផ្សាយភាពចង្អៀតនៅពន្ធនាគារ នៅកើនឡើង។

## លទ្ធភាពផ្ទុកនៅពន្ធនាគារកម្ពុជា

| ពន្ធនាគារ | លទ្ធភាពផ្ទុក | ចំនួន (ខែមិថុនា ឆ្នាំ២០១០) | ភាគរយ |
|---|---|---|---|
| ប៉េហ្ស៊ី | ២០០ | ១៦៧ | ៨៣.៥% |
| ម១ | ១,៦០០ | ២,៦៤៤ | ១៦៥% |
| ម២ | ៣០០ | ៧៧៧ | ២៥៩% |
| ម៣ | ៧២០ | ១,៥២៩ | ២១២% |
| ម៤ | ១៤០ | ១៥៤ | ១១០% |
| ទួលស្លែង[៩] | ៥ | ២ | ៤០% |
| តាខ្មៅ | ៣១៤ | ១,០៤២ | ៣៣២% |
| ព្រះសីហនុ | ១៥០ | ៣៣២ | ២២១% |
| កំពង់ស្ពឺ | ១៨០ | ៣១៣ | ១៧៤% |
| កំពត | ១៦០ | ៣៤៥ | ២១៦% |
| កំពង់ឆ្នាំង | ១៥០ | ២៧១ | ១៨១% |
| កំពង់ចាម | ៥០០ | ៧៩៨ | ១៦០% |
| កំពង់ធំ | ៥០ | ២០៨ | ៤១៦% |
| កោះកុង | ១៥០ | ២១៨ | ១៤៥% |
| ពោធិ៍សាត់ | ១២០ | ២២៩ | ១៩១% |
| បាត់ដំបង | ៦០០ | ១,១៧៤ | ១៩៦% |

[៩] ពន្ធនាគារយោធាឃ្លាំមើលដោយអង្គការលីកាដូ ប៉ុន្តែកិច្ចការរដ្ឋបាលមិនស្ថិតក្រោមក្រសួងមហាផ្ទៃ និងអគ្គនាយកដ្ឋានពន្ធនាគារឡើយ ។

| | | | |
|---|---|---|---|
| **បន្ទាយមានជ័យ** | ៧០០ | ៨១៦ | ១២១% |
| **សៀមរាប** | ១,០០០ | ១,៣៦១ | ១៣៦% |
| **ស្វាយរៀង** | ១៦០ | ២៦៦ | ១៦៦% |
| **សរុប** | **៧,១៩៩** | **១២,៦៤៦** | **១៧៥.៧%** |

## អត្រាខ្ពស់ខ្លាំងនៃកំណើនអ្នកទោស

នៅចន្លោះខែធ្នូ ឆ្នាំ២០០៨ និងខែធ្នូ ឆ្នាំ២០០៩ លីកាដូ បានកត់សំគាល់ឃើញស្ថិតិអ្នកទោសមានការកើនឡើងចំនួន ១៥.៥% នៅក្នុងពន្ធនាគារទាំង ១៨ ដែលលីកាដូបានឃ្លាំមើល។ នៅក្នុងកំឡុងពេលពីខែធ្នូ ឆ្នាំ២០០៧ និងខែធ្នូ ឆ្នាំ២០០៨ ចំនួនអ្នកទោសកើនឡើងត្រឹម ៩.៧% ប៉ុណ្ណោះ។ តាំងពីឆ្នាំ២០០៤ រហូតមក ចំនួនអ្នកទោសក្នុងពន្ធនាគារកើនឡើងស្ទើរទ្វេដង។



*បន្ទប់អ្នកទោសបុរសនៃពន្ធនាគារខេត្តកំពង់ធំផ្ទុកអ្នកទោស ១០០នាក់ លើសពីសមត្ថភាពពីរដង ចំណែកអ្នកទោសបុរសផ្សេងគេងនៅក្រៅបន្ទប់ក្រោមតង់*

ត្រឡប់ទៅខែធ្នូ ឆ្នាំ១៩៩៩ ពន្ធនាគារដែលឃ្លាំមើលដោយលីកាដូ មានចំនួនប្រមាណតែ ៣,៥០០នាក់[១០] មានន័យថា ចំនួនអ្នកទោសបានកើនឡើងស្ទើរតែ ៣៥០%ក្នុងរយៈពេល១០ឆ្នាំ[១១]។

តារាងខាងក្រោមនេះ បង្ហាញនូវការកើនឡើងជាលំដាប់នូវចំនួនអ្នកទោស ក្នុងរយៈពេលប្រាំឆ្នាំនៅពន្ធនាគារ ដែលអង្គការលីកាដូ បានឃ្លាំមើលៈ

[១០] សូមអានរបាយការណ៍លីកាដូ សិទ្ធិមនុស្ស និងពន្ធនាគារកម្ពុជា : ស្ថានភាពពន្ធនាគារឆ្នាំ២០០២-២០០៣ និងខែតុលា ឆ្នាំ២០០៤ ទំព័រទី៦

[១១] គួរឱ្យចាប់អារម្មណ៍នោះគឺ ប្រមាណ ៣៥% នៃអ្នកទោសកម្ពុជាក្នុងឆ្នាំ១៩៩៩ គឺជាពិរុទ្ធជន។ នៅក្នុងអន្តរឆ្នាំ ទិន្នន័យរបស់លីកាដូ បានបង្ហាញថាចំនួននេះ ត្រូវបានធ្លាក់ចុះដល់ ២៨.១% នៅក្នុងឆ្នាំ២០០៦ និង ២៦% នៅឆ្នាំ២០០៧។ ចំនួននេះបានងើបឡើងវិញដល់ ៣០.៨% ក្នុងឆ្នាំ២០០៨ ៣៣.២% ក្នុងឆ្នាំ២០០៩ និងធ្លាក់ចុះវិញ ៣០% ក្នុងខែមិថុនា ឆ្នាំ២០១០។

| ឆ្នាំ | ទណ្ឌិត | ពិរុទ្ធជន | សរុប |
|---|---|---|---|
| ខែធ្នូ ឆ្នាំ២០០៤ | ៤,២០២ | ២,០៩៤ | ៦,២៩៦ |
| ខែធ្នូ ឆ្នាំ២០០៥<br>បម្រែបម្រួលធៀបឆ្នាំមុន | ៥,៦១១<br>(៣៥.៥%) | ២,៦២៧<br>(២៥.៤%) | ៨,២៣៨<br>(៣០.៨%) |
| ខែធ្នូ ឆ្នាំ២០០៦<br>(បម្រែបម្រួលធៀបឆ្នាំមុន) | ៦,៥៤៥<br>(១៦.៦%) | ២,៥៦១<br>(២.៥%) | ៩,១០៦<br>(១០.៥%) |
| ខែធ្នូ ឆ្នាំ២០០៧<br>(បម្រែបម្រួលធៀបឆ្នាំមុន) | ៧,០៧៥<br>(៨.១%) | ២,៥៧៩<br>(១%) | ៩,៦៥៤<br>(៦%) |
| ខែធ្នូ ឆ្នាំ២០០៨<br>(បម្រែបម្រួលធៀបឆ្នាំមុន) | ៧,៣២៥<br>(៣.៥%) | ៣,២៦៧<br>(២៦.៧%) | ១០,៥៩២<br>(៩.៧%) |
| ខែធ្នូ ឆ្នាំ២០០៩<br>(បម្រែបម្រួលធៀបឆ្នាំមុន) | ៨,១៧៣<br>(១១.៦%) | ៤,០៥៨<br>(២៤.២%) | ១២,២៣១<br>(១៥.៥%) |
| កំណើនជាមធ្យម<br>ឆ្នាំ២០០៥-២០០៩ | ១៤.២៣% | ១៤.១៥% | ១៤.២% |



អត្រាកំណើននេះនៅតែខ្ពស់ដដែល សូម្បីតែពន្ធនាគារដែលទើបតែនឹងសង់ឡើង ដើម្បីកាត់បន្ថយភាពចង្អៀតណែន ក៏ដោយ តួយ៉ាងដូចជាពន្ធនាគារៈ

- **ពន្ធនាគារខេត្តសៀមរាប** ជាពន្ធនាគារដែលផ្លាស់ប្តូរទីតាំង និងទីបតែនឹងសាងសង់ថ្មីលើកទី២ ចាប់តាំងពីឆ្នាំ ២០០២មក ហើយត្រូវបានកសាងរួចក្នុងឆ្នាំ២០០៩។ ពន្ធនាគារនេះត្រូវបានកសាងឡើងដើម្បីដាក់អ្នកទោស ១,០០០នាក់។ នេះជាការជំនួសឱ្យអគារពន្ធនាគារចាស់ដែលមានសមត្ថភាពដាក់បានត្រឹមតែ ៥៥០នាក់។ ប៉ុន្តែនៅពេលដែលពន្ធនាគារថ្មីនេះ ត្រូវបានកសាងរួចចំនួនអ្នកទោសមានរហូតដល់ ១,២០០នាក់ រួចជាស្រេច ហើយមកដល់ខែមិថុនា ឆ្នាំ២០១០ ពន្ធនាគារនេះមានអ្នកទោសរហូតដល់ ១,៣៦១ នាក់។

- **ពន្ធនាគារខេត្តបន្ទាយមានជ័យ** ជាពន្ធនាគារដែលផ្លាស់ប្តូរទីតាំង និងទើបតែសាងសង់ថ្មីនៅឆ្នាំ២០០៩ ដែលមានលទ្ធភាពអាចផ្ទុកអ្នកទោសបាន ៧០០នាក់។ នៅពេលកំពុងសាងសង់ពន្ធនាគារខេត្តនេះ មានអ្នកទោសប្រមាណ ៥៥០នាក់ រួចជាស្រេច ត្រឹមតែ១ឆ្នាំក្រោយពេលដែលពន្ធនាគារថ្មីត្រូវសាងសង់រួចប៉ុណ្ណោះ ចំនួនអ្នកទោសបានកើនឡើងហួសពីលទ្ធភាពពន្ធនាគារ ដែលបានគ្រោងទុកដោយមានអ្នកទោសរហូតដល់ ៨១៦ នាក់។

- **ពន្ធនាគារតំរូ តាខ្មៅ** ជាជំនួយរបស់រដ្ឋាភិបាលអូស្ត្រាលី នៅឆ្នាំ២០០៦ ដែលគ្រោងលើលទ្ធភាពអាចផ្ទុកបាន ៣១៤ នាក់ ។ ប៉ុន្តែរហូតមកដល់ខែមិថុនា ឆ្នាំ២០១០ ពន្ធនាគារនេះមានអ្នកទោសរហូតដល់ ១,០៤២ នាក់។

**អត្រាអ្នកទោសនៅក្នុងប្រទេសកម្ពុជាក្នុង ១០០,០០០នាក់**[១២]

| ឆ្នាំ | ចំនួនពលរដ្ឋទូទាំងប្រទេស | ចំនួនអ្នកទោស | ចំនួនអ្នកទោសក្នុង១០០,០០០នាក់ |
|---|---|---|---|
| ២០០៦ | ១៤,០៩១,៨២៣ | ៩,១០៦ | ៦៤.៦ |
| ២០០៧ | ១៤,៣២៣,៨៤២ | ៩,៦៩៤ | ៦៧.៤ |
| ២០០៨ | ១៤,៥៦២,០០៨ | ១០,៥៩២ | ៧២.៧ |
| ២០០៩ | ១៤,៨០០,០០០ | ១២,២៣១ | ៨២.៦ |
| ២០១០ | ១៥,០៣៦,៨០០ | ១៣,៤៩៤ | ៨៩.៤ |

[១២] យោងស្ថិតិរបស់ធនាគារពិភពលោក ដែលអាចពិនិត្យមើលបាននៅក្នុងគេហទំព័រ http://data.worldbank.org/data-catalog/world-development-indicators/wdi-2009) និងស្ថិតិស្រាវជ្រាវពន្ធនាគាររបស់អង្គការលីកាដូ

**សំគាល់:** *ទិន្នន័យនៅឆ្នាំ២០១០ ឃើញថាកំណើនប្រជាពលរដ្ឋកំណើន១.៦% ប៉ុន្តែកំណើនអ្នកទោសមានរហូតដល់ ១០% ។ ទិន្នន័យនេះសម្រាប់តែពន្ធនាគារ ដែលអង្គការលីកាដូ ឃ្លាំមើលតែប៉ុណ្ណោះ ។*

ផែនការដើម្បីរក្សាពន្ធនាគារឱ្យស្ថិតនៅក្រោមចំណុះ នៅពេលអនាគតហាក់ដូចជាមិនសូវមានសង្ឃឹមច្រើនទេ: ប្រសិនបើពន្ធនាគារទាំងអស់នៅតែរក្សាកំណើនត្រឹម ១០%[១៣] ក្នុង១ឆ្នាំ នោះនៅកម្ពុជានឹងត្រូវការកសាងពន្ធនាគារថ្មីៗបន្ថែម ដែលមានទំហំស្មើមណ្ឌលអប់រំកែប្រែទី៤ អោយបានយ៉ាងហោចណាស់មួយជារៀងរាល់ឆ្នាំ។ ទោះជាបែបនេះក៏ដោយ វានៅតែមិនទាន់ឆ្លើយតបទៅនឹងបរិមាណអ្នកទោស ដែលចេះតែកើនឡើងឥតឈប់ឈរនេះឡើយ ។ ឧបមាថា យើងធ្វើការប៉ាន់ប្រមាណ ដោយគ្រោងត្រឹមតែថែមអាគារឃុំឃាំង សំរាប់មនុស្សចំនួន ៤០០ ក្នុង ១ឆ្នាំ សម្រាប់រយៈពេល ៩ឆ្នាំ[១៤] ខាងមុខ ហើយបើសន្មតនូវអត្រាកំណើនត្រឹម ៥% ក្នុងកំឡុងពេលនោះៗ បរិមាណអ្នកទោសពន្ធនាគារកម្ពុជា ក៏អាចនៅតែហៀរហូរ លើសចំនុះក្នុងកម្រិត ១៦៥% នៅឆ្នាំ២០១៩ ដែរ ។

ឧមាថានេះជាករណីដ៏អាក្រក់ នៃការបន្តកើនឡើងជាង១៤% ក្នុងរយៈពេល៩ឆ្នាំកន្លងទៅ បូករួមទាំងការបន្ថែមបន្ទប់សម្រាប់អ្នកទោស ៤០០នាក់ ក្នុងមួយឆ្នាំជាមធ្យម នោះប្រទេសកម្ពុជាអាចក្លាយជាពន្ធនាគារចង្អៀតជាងគេបំផុតលើពិភពលោកនៅឆ្នាំ២០១៨[១៥] ។

តារាងខាងក្រោម គឺជាការប៉ាន់ប្រមាណនូវអត្រាកំណើន ៣ ខុសៗគ្នា គឺ ៥% ៧% និង ១០% ប្រចាំឆ្នាំ ជាមួយការសន្មតថា មានការកសាងពន្ធនាគារបន្ថែមដែលមានបន្ទប់ឃុំឃាំងសំរាប់មនុស្សចំនួន ៤០០ ទៅ ១,០០០ និង ២,៥០០ នាក់ ក្នុងមួយឆ្នាំៗ។ តួលេខ "**បច្ចុប្បន្ន**" គឺផ្អែកលើលទ្ធភាព និងចំនួនអ្នកទោសនៅក្នុងពន្ធនាគារទាំងអស់ដែលមាននៅក្នុងរបាយការណ៍ របស់អគ្គនាយកដ្ឋានពន្ធនាគារនាខែមីនា ឆ្នាំ២០១០ កន្លងទៅ:

[១៣] អត្រាកំណើន ១០% ឬ ខ្ពស់ជាងនេះ គឺទំនងជានៅតែកើន ជាពិសេសនៅពេលដែលផ្នែកខ្លះនៃក្រមព្រហ្មទណ្ឌថ្មី ដែលនៅសេស សល់ចូលជាធរមាននៅខែធ្នូ ឆ្នាំ២០១០ ខាងមុខនេះ។ នៅក្នុងច្បាប់នេះមានចែងអំពី ទោសព្រហ្មទណ្ឌជាង ៣០០ ចំណុច រីឯច្បាប់ព្រហ្មទណ្ឌ អន្តរកាលវិញ មានចែងត្រឹមតែ ៣៥ ចំណុច ប៉ុណ្ណោះ។ (ប្រៀបធៀបជាមួយក្រមព្រហ្មទណ្ឌអន្តរកាលចំណងជើងលេខ IV និង V និង ក្រមព្រហ្មទណ្ឌចំណងជើងលេខ II -IV)។ លើសពីនេះទៅទៀត បទល្មើសមួយចំនួនដែលច្បាប់ចាស់កំណត់ទោសត្រឹមតែផាកពិន័យ ច្បាប់ថ្មីប្ដូរទៅជាបទព្រហ្មទណ្ឌទាំងអស់ ដែលប្រការនេះនឹងធ្វើឱ្យចំនួនជនជាប់ចោទដែល ត្រូវដាក់ពន្ធនាគារកើនឡើងកាន់តែច្រើនដោយសារតែពុំ មានលទ្ធភាពសងជាថវិកា។

[១៤] ការថែមបន្ទប់ឃុំឃាំងសម្រាប់អ្នកទោស៤០០នាក់ ក្នុង ១ឆ្នាំ គឺប្រហាក់ប្រហែលនឹងអត្រានាពេលបច្ចុប្បន្ន។ ហើយអត្រានេះអាចជាអត្រាមួយមានលក្ខណៈសុទិដ្ឋិនិយម ពីព្រោះវាស្ថិតក្រោមសម័យកាលនៃការកសាងដែលមានការកើនឡើងយ៉ាងខ្លាំងដោយជំនួយបរទេសមួយផ្នែក។ នៅចន្លោះឆ្នាំ២០០៧ និង ២០០៩ ប្រព័ន្ធពន្ធនាគារកម្ពុជា ថែមបន្ទប់ឃុំឃាំងសម្រាប់អ្នកទោស ៣០០នាក់ ជាមធ្យមក្នុង ១ ឆ្នាំ។ បន្ថែម ឆ្នាំ២០១០ កំណើនបន្ទប់ឃមុឃាំងអ្នកទោស ៤០០នាក់ ក្នុង ១ឆ្នាំ ជាធម្យម សន្មតថាពន្ធនាគារខេត្តកំពង់ធំ កសាងថ្មីរួច និងថែមបន្ទប់សម្រាប់អ្នកទោស ២០០នាក់ ទៀតនៅមណ្ឌលកែប្រែទី ៤។

[១៥] ព័ត៌មានលំអិត សូមមើលនៅក្នុងសកលវិទ្យាល័យឃីង នៃមជ្ឈមណ្ឌលទីក្រុងឡុងដ៏អន្តរជាតិសម្រាប់ការសិក្សាពន្ធនាគារ" ពិភពលោកទាំងមូល-អត្រា ឃុំឃាំង " ព័ត៌មានលំអិត សូមមើលនៅក្នុងគេហទំព័រ:http://www.kcl.ac.uk/depsta/law/research/icps/worldbrief/wpb_stats.php?area=all&category=wb_0ccupancy

| ឆ្នាំ | ថៃមបន្ទប់សម្រាប់អ្នកទោស ៨០០នាក់/ ឆ្នាំ (អត្រាបច្ចុប្បន្ន) | ថៃមបន្ទប់សម្រាប់អ្នកទោស ១,០០០នាក់/ឆ្នាំ | ថៃមបន្ទប់សម្រាប់អ្នកទោស ២,៥០០ នាក់/ឆ្នាំ (ម៤) | អត្រាកំណើន ៥%/ឆ្នាំ | អត្រាកំណើន ១០%/ឆ្នាំ | អត្រាកំណើន ១៤%/ឆ្នាំ (អត្រាបច្ចុប្បន្នជាមធ្យម) |
|---|---|---|---|---|---|---|
| ២០១០ | ៨,០០០ (បច្ចុប្បន្ន) | ៨,០០០ (បច្ចុប្បន្ន) | ៨,០០០ (បច្ចុប្បន្ន) | ១៣,៣២៥ (បច្ចុប្បន្ន) | .. | .. |
| ២០១១ | ៨,៤០០ | ៩,០០០ | ១០,៥០០ | ១៣,៩៩១ | ១៤,៦៥៧ | ១៥,១៩០ |
| ២០១២ | ៨,៨០០ | ១០,០០០ | ១៣,០០០ | ១៤,៦៩០ | ១៦,១២៣ | ១៧,៣១៧ |
| ២០១៣ | ៩,២០០ | ១១,០០០ | ១៥,៥០០ | ១៥,៤២៥ | ១៧,៧៣៥ | ១៩,៧៤១ |
| ២០១៤ | ៩,៦០០ | ១២,០០០ | ១៨,០០០ | ១៦,១៩៦ | ១៩,៥០៨ | ២២,៥០៤ |
| ២០១៥ | ១០,០០០ | ១៣,០០០ | ២០,៥០០ | ១៧,០០៦ | ២១,៤៥៩ | ២៥,៦៥៤ |
| ២០១៦ | ១០,៤០០ | ១៤,០០០ | ២៣,០០០ | ១៧,៨៥៦ | ២៣,៦០៥ | ២៩,២៤៥ |
| ២០១៧ | ១០,៨០០ | ១៥,០០០ | ២៥,៥០០ | ១៨,៧៤៩ | ២៥,៩៦៦ | ៣៣,៣៣៩ |
| ២០១៨ | ១១.២០០ | ១៦,០០០ | ២៨,០០០ | ១៩,៦៨៧ | ២៨,៥៦២ | ៣៨,០០៦ |
| ២០១៩ | ១១,៦០០ | ១៧,០០០ | ៣០,៥០០ | ២០,៦៧១ | ៣១,៤១៩ | ៤៣,៣២៦ |

*(តួលេខពណ៌ក្រហម គឺជាតួលេខ ដែលសន្មតចំនួនអ្នកទោសសរុប ដែលអាចកើនឡើងហួសពីចំណុះពន្ធនាគារទោះបីជាអគ្គនាយកដ្ឋានពន្ធនាគារលើកឡើងថា នឹងថែមបន្ទប់ឃុំឃាំងសំរាប់មនុស្សចំនួន ២,៥០០ ទៀតក្នុងមួយឆ្នាំក៏ដោយ)*

កម្ពុជាពុំអាចកសាងពន្ធនាគារឱ្យលឿនទាន់ នៃល្បឿនកំណើនអ្នកទោសដែលចេះតែកើនឡើងនាពេលបច្ចុប្បន្ននេះទេ ម្យ៉ាងទៀតថវិកាសំរាប់សាងសង់ពន្ធនាគារនៅមានកំរិតនៅឡើយ។ ការកសាងពន្ធនាគារ និងការឃុំឃាំងអ្នកទោសឱ្យបានសមស្របតាមលក្ខខណ្ឌ/ស្តង់ដាអន្តរជាតិ ចាំបាច់ត្រូវចំណាយច្រើនណាស់។ ហើយមកដល់ពេលនេះ យោងតាមមន្ត្រីដែលផ្តល់សម្ភាសន៍ជាមួយលីកាដូ បានអោយដឹងថា នៅពេលនេះពន្ធនាគារជួបប្រទះនូវកង្វះខាតថវិកាក្នុងការកសាងមណ្ឌលអប់រំកែប្រែទី៤ ហើយ។ ម្យ៉ាងវិញទៀត វាជាករណីកម្រណាស់នាពេលកន្លងមក ដែលពន្ធនាគារថ្មីណាមួយអាចបញ្ចប់គម្រោងសាងសង់ដោយថវិការដ្ឋ។ តាមធម្មតាសាងសង់ពន្ធនាគារថ្មីបែបនេះ ច្រើនតែត្រូវបានជួយកសាងបង្ហើយ និងកែលំអរដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ ឬ អន្តរជាតិ[១៦]។

[១៦] ឧទាហរណ៍ កាលពីខែមករា ឆ្នាំ២០១០ កន្លងទៅ មន្ត្រីជាន់ខ្ពស់ម្នាក់បានមានប្រសាសន៍ប្រាប់អង្គការលីកាដូថា ពន្ធនាគារនៅខេត្តកំពង់ធំ គ្រោងបើកប្រើ ប្រាស់នៅក្នុងរដូវប្រាំងឆ្នាំនេះ ប៉ុន្តែនៅមានការខ្វះខាតច្រើនដូចជា: ទឹក អគ្គិសនី បន្ទប់ឃុំឃាំង និងអគារបន្ទាប់បន្សំ មួយចំនួន រួមមាន: គ្លីនិក អគារសម្រាប់ ហ្វឹកហ្វឺនជាដើម។ មូលហេតុដែលនាំឱ្យមានការខ្វះខាតទាំងអស់នេះគឺថវិកា។ កង្វះទឹក និងអគ្គិសនី គឺជាបញ្ហាដែលមិនអាចខ្វះបានទេ ដោយហេតុថា ប្រភពបណ្តាញទឹកមេ និងអគ្គីសនី ស្ថិតនៅមិនឆ្ងាយជាង ១ គម ពីពន្ធនាគារនោះផង។ មន្ត្រីនោះបានបញ្ជាក់ថែម

តើថវិកាសម្រាប់ការកសាងបន្ថែមបានមកពីណា?

## កត្តារួមផ្សំបណ្តាលអោយមានបញ្ហាចង្អៀតខ្លាំង

បញ្ហាចង្អៀតគឺជាលទ្ធផលនៃកត្តារួមផ្សំជាច្រើន។ ប៉ុន្តែអ្វីដែលសំខាន់នោះគឺ ការពឹងផ្អែកលើសលប់លើពន្ធនាគារ តែម្យ៉ាងដើម្បីដោះស្រាយបញ្ហានេះ។

បច្ចុប្បន្ននេះ ប្រព័ន្ធយុត្តិធម៌កម្ពុជា គឺផ្តោតការយកចិត្តទុកដាក់ស្ទើរតែទាំងស្រុងលើការឃុំឃាំងទាំងទណ្ឌិត និងពិរុទ្ធជន ដែលរង់ចាំសវនាការ។ ការផ្តន្ទាទោស ស្ទើរតែគ្រប់បទល្មើសទាំងអស់គឺ ត្រូវដាក់ពន្ធនាគារសូម្បីតែបទល្មើសស្រាលក៏ដោយ ហើយច្រើនតែជាប់ក្នុងរយៈពេលមួយយូរទៀតផង។ ដូចគ្នានេះដែរ ការដាក់អោយជនត្រូវចោទនៃបទល្មើសព្រហ្មទណ្ឌឱ្យនៅក្រៅឃុំរងចាំសវនាការ គឺជាករណីកម្រណាស់ ភាគច្រើនត្រូវឃុំឃាំងបណ្តោះអាសន្នរងចាំការបើកសវនាការជំនុំជំរះក្តី។

*" ប្រសិនបើពន្ធនាគារទាំងអស់នៅតែរក្សាកំណើនត្រឹម ១០% ក្នុង១ឆ្នាំ នោះនៅកម្ពុជានឹងត្រូវការកសាង ពន្ធនាគារថ្មីៗបន្ថែម ដែលមានទំហំស្មើមណ្ឌលអប់រំកែប្រែទី៤ អោយបានយ៉ាងហោចណាស់មួយជារៀងរាល់ឆ្នាំ។ ទោះជាបែបនេះក៏ដោយ វានៅតែមិនទាន់ឆ្លើយតបទៅនិងបរិមាណអ្នកទោស ដែលចេះតែកើនឡើងឥតឈប់ឈរ នេះឡើយ "*

លីកាដូ កន្លងមកបានកត់ត្រានូវករណីជាច្រើនដែលត្រូវបានឃុំឃាំងលើសថេរវេលាកំណត់នៃច្បាប់។ ការឃុំឃាំងមនុស្សម្នាក់ ហើយម្នាក់ទៀត ដែលក្នុងនោះមានករណីខ្លះគួរតែពិចារណា លើការដាក់ឱ្យនៅក្រៅឃុំបណ្តោះអាសន្ន ប៉ុន្តែការសម្រេចចិត្តភាគច្រើនរបស់ចៅក្រមភ្លេចគិតថាពន្ធនាគារស្ទើរតែប្រេះថ្មេរបែកធ្លាយទៅហើយទេ។ មនុស្សទាំងនោះរួមមាន:

- ពិរុទ្ធជនដែលជាប់ឃុំឃាំងបណ្តោះអាសន្នរងចាំសវនាការលើសថេរវេលាកំណត់ដោយច្បាប់[១៧]។
- រហូតមកដល់ ខែឧសភា ឆ្នាំ២០១០ កន្លងទៅនេះ យ៉ាងតិចណាស់ក៏មាន ៩១ ករណីបានកើតឡើងនៅក្នុងពន្ធនាគារទាំង១៨ ដែលលីកាដូ ឃ្លាំមើល[១៨]។

---

ទៀតថា បញ្ហានេះប្រហែលត្រូវសុំជំនួយពី "អង្គការមិនមែនរដ្ឋាភិបាល" ដើម្បីជួយគាត់បង្ហើយការសាងសង់នេះ។ មានបន្ទប់ឃុំឃាំងខ្លះត្រូវបានសាងសង់រួចរាល់ហើយកាលពីខែមេសា ឆ្នាំ២០១០ ប៉ុន្តែរហូតមកដល់កក្កដានេះ ពន្ធនាគារនេះ នៅមិនទាន់ដាក់ អោយដំណើរការនៅឡើយ។

[១៧] សូមអានរបាយការណ៍ ដែលមានចំណងជើងថា: សិទ្ធិមនុស្ស និង ពន្ធនាគារកម្ពុជា: ស្ថានភាពពន្ធនាគារ ឆ្នាំ២០០៤ ខែធ្នូ ឆ្នាំ២០០៥ ទំព័រទី២០។ រយៈពេលកំណត់សម្រាប់ឃុំឃាំងអនីតិជនគឺចន្លោះពី ២ខែ សម្រាប់យុវជនដែលត្រូវចោទដោយបទល្មើសកម្រិតស្រាលរហូត ១៨ខែ សម្រាប់មនុស្សពេញវ័យដែលត្រូវចោទពីបទព្រហ្មទណ្ឌ។ សូមអាន ក្រមនីតិវិធី ព្រហ្មទណ្ឌ-មាត្រា ២០៨ និង ២១៤។

[១៨] អគ្គនាយកដ្ឋានពន្ធនាគារផ្ទាល់បានអះអាងកាលពីខែសីហា ឆ្នាំ២០០៩ កន្លងទៅថាមានករណី "ឃុំឃាំងលើសថេរវេលាកំណត់ " ចំនួន ៧៥៥ ករណី ប៉ុន្តែវិធីសាស្រ្តក្នុងការគណនារបស់អគ្គនាយកដ្ឋានពន្ធនាគារមិនសូវច្បាស់លាស់ទេ។ ថេរវេលាក្នុងការឃុំឃាំងបណ្តោះអាសន្នត្រូវបានកំណត់ដោយតុលាការ ប៉ុន្តែពុំសូវមានភាពជាក់លាក់ទេ ហើយចំនួននេះទំនងជារាប់បញ្ចូលទាំងករណីទាំងឡាយដែលព្រះរាជអាជ្ញា និងតុលាការមិនបានអនុវត្តឱ្យបានទាន់ពេលវេលាត្រឹមត្រូវផងដែរចំពោះការបន្តឃុំឃាំងបែបនេះ។ សូមអានរបាយការណ៍ ស្តីពីការរីកចំរើនរបស់អគ្គនាយកដ្ឋានពន្ធនាគារ ទំព័រទី៦។

- ទណ្ឌិតដែលត្រូវបានឃុំឃាំងលើសថេរវេលាកំណត់នៃទោស[១៩]
- ពិរុទ្ធជនដែលជាប់ឃុំឃាំងបណ្តោះអាសន្ន ត្រូវឃុំលើសកម្រិតអតិបរមានៃទោសក្នុងបទល្មើស ដែលត្រូវបានចោទប្រកាន់។
- អ្នកទោសជាប់បណ្តឹងឧទ្ធរណ៍ ហើយជាប់នៅក្នុងឃុំលើសកម្រិតអតិបរមានៃទោសដែលត្រូវបានកំណត់។ ករណីដ៏កំសត់បំផុតនោះគឺ ជនត្រូវចោទដែលត្រូវបានលើកលែងការចោទប្រកាន់ហើយ នាពេលសវនាការសាលាដំបូង ប៉ុន្តែត្រូវជាប់ឃុំតទៅទៀត ដោយសារតែជាប់បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា[២០]។
- ការផ្តោតតែទៅលើការបញ្ជូនជនត្រូវចោទទៅដាក់ពន្ធនាគារជាអាទិភាពនោះ វាជាការវិបាកមួយដែលមិនអាចចៀសផុតបាន នៃការដែលមានកំណើនអ្នកទោសឥតឈប់ឈរ ដែលនេះហើយ គឺជាមូលហេតុនៃការចង្អៀតណែននៃពន្ធនាគារនោះ។

## ជម្រើសផ្សេងៗក្រៅពីការឃុំខ្លួនក្នុងពន្ធនាគារ : អាចធ្វើទៅបាន មានប្រសិទ្ធិភាព និងមានលក្ខណមនុស្សធម៌ផង

អគ្គនាយកដ្ឋានពន្ធនាគារ មិនអាចដោះស្រាយបញ្ហាចង្អៀតណែនដោយខ្លួនឯងបានទេ។ វិធីសាស្ត្រដ៏មានប្រសិទ្ធិភាពគឺ តម្រូវឱ្យមានការផ្លាស់ប្តូរជាមូលដ្ឋាននៅក្នុងប្រព័ន្ធយុត្តិធម៌កម្ពុជា។ ដំណោះស្រាយមួយចំពោះបញ្ហាចង្អៀតណែននេះ គឺតុលាការ និងព្រះរាជអាជ្ញា គួរពិចារណានូវការផ្តន្ទាទោស ដោយជ្រើសរើសនូវជម្រើសផ្សេងៗទៀតក្រៅពីការបញ្ជូនមនុស្សដាក់ពន្ធនាគារ ដូចជា ការព្យួរទោស ការពិន័យជាប្រាក់ ចំពោះបទល្មើសមធ្យម និងធ្វើការកាត់បន្ថយជាអតិបរិមា នូវវិធានការឃុំឃាំងបណ្តោះអាសន្នចំពោះជនត្រូវចោទក្នុងបទល្មើសមធ្យមផងដែរ។

រដ្ឋាភិបាល គួរចាប់ផ្តើមពិនិត្យនូវបញ្ហាការឃុំខ្លួនបណ្តោះអាសន្នរងចាំការបើកសវនាការនេះ មកធ្វើការដោះស្រាយ[២១]។ ដោយហេតុថា មានពិរុទ្ធជនប្រហែលជា ៣,៨០០ នាក់ កំពុងជាប់ឃុំនៅក្នុងពន្ធនាគារកម្ពុជា ដែលវត្តមាននេះ ធ្វើអោយរាជរដ្ឋាភិបាលមានបន្ទុកកាន់តែធ្ងន់ក្នុងការដោះស្រាយលើជីវភាពរបស់អ្នកទោស និងតម្រូវការផ្សេងៗទៀត។

[១៩] បញ្ហានេះអាចកើតឡើងដោយសារតែមានការយឺតយ៉ាវនូវនីតិវិធីរដ្ឋបាលក្នុងការរៀបចំឯកសារដោះលែង អាចជាឧបសគ្គ ដោយសារមន្ត្រី ពន្ធនាគារឆ្លៀតរកប្រាក់ចំណូលបន្ថែមពីអ្នកទោសក្នុងការរៀបចំឯកសារ ឬ ដោយសារតែបញ្ហាទាំងពីរខាងលើ។

[២០] មាត្រា ៣៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា ជនជាប់ចោទត្រូវបន្តជាប់ឃុំឃាំងតទៅទៀតរងចាំដំណោះស្រាយរបស់សាលាឧទ្ធរណ៍។ ប៉ុន្តែមាត្រាដដែលនេះក៏បានចែងផងដែរថា ព្រះរាជអាជ្ញា "អាចដោះលែងជនជាប់ចោទមុនដល់ពេលកំណត់បណ្តឹងឧទ្ធរណ៍បាន" ប្រសិនបើចុង ចោទត្រូវបានលើកលែងការចោទប្រកាន់នៅសាលាដំបូង ឬ ត្រូវបានកាត់ឱ្យជាប់ពន្ធនាគារស្មើ ឬ ខ្លីជាងរយៈពេលដែលជននោះបានជាប់ឃុំបណ្តោះអាសន្ន"។ ការចែងច្បាប់ត្រង់ចំណុចនេះមិនទាន់បានគិតឱ្យស៊ីជម្រៅទេ ដោយបានផ្តល់នូវឆន្ទានុសិទ្ធិឱ្យភាគីម្ខាងដែលអាចលំអៀងគឺ ព្រះរាជអាជ្ញាដែលជាអ្នកធ្វើការចោទប្រកាន់។ យ៉ាងណាក៏ដោយ ក៏លីកាដូទាមទារឱ្យព្រះរាជអាជ្ញា ប្រើប្រាស់មាត្រាទាំងនេះ តទៅទៀត។

[២១] ទោះបីជាក្រមនីតិវិធីព្រហ្មទណ្ឌចែងថា ចុងចោទអាចស្នើសុំឱ្យមានការដោះលែងរងចាំសវនាការ ក៏អំណាចក្នុងការសម្រេចចិត្តស្ថិតនៅលើតុលាការដែរ ហើយនៅក្នុងករណីខ្លះ ក៏ត្រូវសម្រេចដោយ ព្រះរាជអាជ្ញាដែរ។ ក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា ២១៥ -១៨។

ជាគោលការណ៍ វិធានការឃុំឃាំងបណ្តោះអាសន្នជនត្រូវចោទ ជាជម្រើសដែលអាច (**លើកលែង**) ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានចែងថា (ជាគោលការណ៍ ជនត្រូវចោទត្រូវតែមានសេរីភាព)[២២] ។ នេះសរបញ្ជាក់អោយឃើញថា ការដាក់អោយជនត្រូវចោទនៅក្រៅឃុំ ដើម្បីរង់ចាំសវនាការវា គឺជាជម្រើសដ៏ប្រសើរមួយ ។ សេរីភាពនេះគួរត្រូវបានផ្តល់ជាស្វ័យប្រវត្តិដល់ជនត្រូវចោទណា ដែលត្រូវបានចោទប្រកាន់លើបទល្មើសមជ្ឈឹមកម្រិតស្រាល ជាពិសេសបទល្មើសដែលមិនប្រើអំពើហិង្សា ឬ ជនដែលមិនអាចគេចខ្លួនទៅឆ្ងាយ ឬ មិនបង្កឱ្យមានគ្រោះថ្នាក់ដល់សហគមន៍ និងសង្គម[២៣] ។

ចំពោះទណ្ឌិត ក្រមព្រហ្មទណ្ឌដែលទើបតែអនុម័តថ្មីៗ[២៤] បានចែងនូវជម្រើសយ៉ាងច្រើន ទាំងការកាត់ទោសដោយមិនឃុំឃាំងទាំងស្រុង និងយន្តការដែលអាចត្រូវបានកាត់បន្ថយទោស ឬ បំព្រួញមកត្រឹមទោសអប្បបរមា ដោយតម្រូវអោយទណ្ឌិតអនុវត្តន៍ ដូចជា:

- ការងារសហគមន៍ (ចំពោះបទល្មើសណាដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគាររហូតដល់ ៣ ឆ្នាំ)[២៥]
- ការស្តីបន្ទោស (កាលបើជនជាប់ចោទរងទោសដាក់ពន្ធនាគារ ដែលមានអតិបរមាតិចជាង ឬស្មើនឹង ៣ឆ្នាំ តុលាការអាចប្រកាសស្តីបន្ទោស ប្រសិនបើមានគ្រប់លក្ខខណ្ឌទាំងបីដូចតទៅ: (១)-ភាពចលាចលដល់សណ្តាប់ធ្នាប់សាធារណៈ ដែលបណ្តាលមកអំពើល្មើសត្រូវបានបញ្ចប់ ។ (២)-ការខូចខាតត្រូវបានជួសជុលរួចហើយ ។ (៣)- ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ[២៦] ។
- ការព្យួរទោស ទាំងមានលក្ខខណ្ឌ ឬ គ្មានលក្ខខណ្ឌ ឬ[២៧]
- ការផ្អាកការប្រកាសទោស ក្នុងករណីចោទប្រកាន់ពីបទមជ្ឈឹម តុលាការក្រោយពីបានប្រកាសថា ជនជាប់ចោទមានពិរុទ្ធ អាចផ្អាកការប្រកាសទោស ប្រសិនបើលក្ខណ្ឌដូចតទៅនេះត្រូវបានបំពេញ: (ភាពច្របូកច្របល់នៃសណ្តាប់ធ្នាប់សាធារណៈ ដែលបង្កឡើយដោយជនល្មើសត្រូវបានបញ្ឈប់ ។ ជនជាប់ចោទបានបង្ហាញការធានា

---

[២២] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ២០៣ ។

[២៣] មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងអំពីការឃុំឃាំងបណ្តោះអាសន្នថា " អាចត្រូវបានបញ្ជា នៅពេលណាដែល *ចាំបាច់* ដើម្បី : (១) បញ្ឈប់បទល្មើស ឬ ទប់ស្កាត់បទល្មើសកុំឱ្យកើតឡើងម្តងទៀត (២) ទប់ស្កាត់កុំឱ្យមានការគំរាមដល់សាក្សី ឬ ជនរងគ្រោះ ឬ ទប់ស្កាត់ពីការឃុបឃិតគ្នារវាងជនដែលត្រូវចោទ និងជនផ្សំគំនិត (៣) រក្សាភស្តុតាង ឬ ការបង្ហាញផ្សេងៗ (៤) ធានាដើម្បីឱ្យជនជាប់ ចោទមានវត្តមានក្នុងកំឡុងមានបណ្តឹងមកលើគាត់ និង (៦) ដើម្បីរក្សាសណ្តាប់ធ្នាក់សាធារណៈ ពីការបង្ករការលំបាកណាមួយដោយបទ ល្មើស" ។ បទបញ្ជាឃុំឃាំងបណ្តោះអាសន្នតម្រូវឱ្យមានការសរសេរជាលាយលក្ខណ៏អក្សរនូវរបាយការណ៏បញ្ជាក់អំពីមូលហេតុផ្អែកលើកត្តាទាំងឡាយដែលមានចែងក្នុងមាត្រា២០៥ ។ សូមអានក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ២០៦ ។

[២៤] មាត្រាចែងអំពីការផ្តន្ទាទោសបានចូលជាធរមានកាលពីខែធ្នូ ឆ្នាំ២០០៩ ហើយផ្នែកដែលនៅសល់ពីនោះនឹងចូលជាធរមាននៅខែធ្នូ ឆ្នាំ២០១០ ។

[២៥] ក្រមព្រហ្មទណ្ឌ មាត្រា ៧២- ៧៥ ។

[២៦] មាត្រា ៧៦ នៃ ច្បាប់ដដែល ។

[២៧] មាត្រា ១១៧-១២៣ នៃច្បាប់ដដែល ។

ក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ និងជនជាប់ចោទសុំ រយៈពេលដើម្បីជួសជុលការខូចខាត)[២៨] ។

- របបពាក់កណ្តាលសេរីភាព កាលណាតុលាការប្រកាសទោសដាក់ពន្ធនាតិចជាង ឬស្មើនឹង ៦ខែ តុលាការអាចសម្រេចថា ទោសត្រូវអនុវត្តក្រោមរបបពាក់កណ្តាលសេរីភាព ដើម្បីអនុញ្ញាតអោយទណ្ឌិតអាចបំពេញសកម្មភាពវិជ្ជាជីវៈ ទទួលការសិក្សា ឬការបណ្តុះបណ្តាល ឬការពិនិត្យព្យាបាលជំងឺ ឬជួយឧបត្ថម្ភដល់សេចក្តីត្រូវការរបស់គ្រួសារ[២៩] ។

- ការបែងចែកទោសជាប្រភាគ កាលណាតុលាការប្រកាសទោសដាក់ពន្ធនាគារតិចជាង ឬស្មើនឹង ១ឆ្នាំ តុលាការអាចសំរេចថា ទោសនោះត្រូវអនុវត្តជាប្រភាគដោយមូលហេតុធ្ងន់ធ្ងរ ដែលមានលក្ខណៈជាគ្រួសារជាវេជ្ជសាស្ត្រ ជាវិជ្ជាជីវៈ ឬជាសង្គម[៣០] ។

- ទណ្ឌកម្មជាច្រើននៅក្នុងក្រមព្រហ្មទណ្ឌថ្មី ដែលអនុញ្ញាតអោយចៅក្រមធ្វើការជំនួសមូលទោស ដោយទោសបន្ថែមបាន ។ ទោសបន្ថែមនេះ តុលាការមិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬទោសពិន័យជាប្រាក់បានទេ[៣១]

**រដ្ឋាភិបាលគួរតែពិចារណាក្នុងការបង្កើតឱ្យមានយន្តការដើម្បីៈ**

- បង្វែរករណីស្រាល១ចេញពីប្រព័ន្ធយុត្តិធម៌ និងព្រហ្មទណ្ឌ ដោយជ្រើសរើសការអនុវត្តន៍ទោសជាមួយ និងប្រព័ន្ធសាមញ្ញ ឬ ជាវិន័យតាមបែបប្រពៃណីនៅក្នុងសហគមន៍ ដោយគោរពនូវបទដ្ឋានសិទ្ធិមនុស្សជាគោល ។ បែបនេះ ជាការផ្តល់ឱកាសឱ្យជនល្មើស ធ្វើការផ្លាស់ប្តូរជាមួយសហគមន៍ ដោយមិនចាំបាច់រំខានដល់ប្រព័ន្ធយុត្តិធម៌ និងព្រហ្មទណ្ឌឡើយ ។

- ជនល្មើសដែលជាអនីតិជន គួរតែរៀបចំឱ្យមានការដាក់ទោស និងអនុវត្តន៍ទោស នូវជម្រើសផ្សេង១ទៀតក្រៅពីដាក់ពន្ធានាគារ ដូចដែលបានអធិប្បាយពីខាងដើម ។ ដោយហេតុថា កម្ពុជាបច្ចុប្បន្នកំពុងឃុំឃាំងជនល្មើសជាអនីតិជនចំនួន ៧៨៨នាក់ ក្នុងនោះអនីតិជន ៣៧៥នាក់ ត្រូវបានជាប់ឃុំលាយឡំជាមួយមនុស្សពេញវ័យនៅក្នុងពន្ធនាគារ[៣២] ។

ការបង្កើននូវយន្តការផ្តន្ទាទោស ដោយមិនប្រើប្រាស់ប្រព័ន្ធពន្ធនាគារ និងវិធានការនៅក្រៅឃុំមុនការ

[២៨] មាត្រា ១២៤-២៦ នៃច្បាប់ដដែល ។

[២៩] មាត្រា ១២៧ - ១៣១ នៃច្បាប់ដដែល ។

[៣០] មាត្រា ១៣២-១៣៥ នៃច្បាប់ដដែល ។

[៣១] មាត្រា ៥៣-៧១ និង ១០០ នៃច្បាប់ដដែល ។

[៣២] នៅមណ្ឌលអប់រំកែប្រែទី២ ជួនកាល គេហៅថា ពន្ធនាគារសម្រាប់ "អនីតិជន" ដោយនៅទីនោះអនីតិជនជាបុរសមិនត្រូវបានគេដាក់លាយឡំជាមួយអ្នកទោសវ័យចំណាស់ជាស្ត្រី ដូចនៅពន្ធនាគារកម្ពុជាដទៃ១ទៀតឡើយ ។ ប៉ុន្តែពន្ធនាគារនោះ ក៏មានឃុំឃាំងមនុស្សពេញវ័យជាស្ត្រី ៣៨៥ នាក់ ដែរ ។

បើកសវនាការជំនុំជំរះ នឹងជួយឱ្យរដ្ឋាភិបាល ទទួលបាននូវការសម្រេចគោលដៅផ្សេងៗទៀតផងដែរ។ ការនៅតែប្រើប្រាស់ប្រព័ន្ធយុត្តិធម៌ និងព្រហ្មទណ្ឌ តែមួយគត់ដើម្បីអប់រំកែប្រែ និងស្តារនីតិសម្បទា វាជាការពិបាកក្នុងការសំរេចបាននូវគោលដៅណាស់។ សូម្បីតែប្រព័ន្ធយុត្តិធម៌ និងព្រហ្មទណ្ឌនេះ បានដំណើការទៅល្អប្រសើក៏ដោយ ក៏ការឃុំឃាំងមនុស្សក្នុងពន្ធនាគារ អាចជាទង្វើមួយដែលកាត់បន្ថយនូវតម្លៃក្នុងភាពមនុស្សជាតិ ដែលនេះធ្វើឱ្យមានផលប៉ះពាល់អវិជ្ជមានដល់លទ្ធភាពរបស់មនុស្សក្នុងការរស់នៅជាធម្មតាក្នុងសង្គម។ ម្យ៉ាងវិញទៀតការផ្តន្ទាទោសដោយមិនប្រើប្រាស់ប្រព័ន្ធពន្ធនាគារនេះ វានឹងបានផលជាវិជ្ជមានមួយចំនួនដល់សង្គមដូចជាៈ

- គឺជាជោគជ័យ ក្នុងការធ្វើសមាហរណកម្ម ដល់ទណ្ឌិតដែលបានអនុវត្តទោសចប់ បានរស់នៅក្នុងសហគមន៏ដោយភាពសុខសាន្ត។ ធ្វើបែបនេះ គឺសហគមន៏ ក៏ដូចជាសង្គមមិនខាតបង់នូវធនធានមនុស្សផងដែរ។

- ផ្តល់ឳកាសដល់ជនត្រូវចោទ (ពិរុទ្ធជន) អាចបន្តការរៀនសូត្រ ប្រកបការងារ និងធ្វើការផ្សេងៗសម្រាប់គ្រួសារបែបនេះ គឺជាការកាត់បន្ថយបន្ទុកដល់សង្គម។

- ផ្តល់ឳកាសដល់ជនត្រូវចោទ (ពិរុទ្ធជន) ឬ ទណ្ឌិត ក្នុងការបន្តជួយឧបត្ថមគាំទ្រដល់សមាជិកគ្រួសាររបស់ខ្លួន។ ដោយហេតុថា អ្នកជាប់ពន្ធនាគារភាគច្រើននៅកម្ពុជា អាចជាអ្នករកស៊ីចិញ្ចឹមគ្រួសារយ៉ាងសំខាន់ ហើយការឃុំឃាំងពួកគេអាចបណ្តាលឱ្យមានការប៉ះពាល់ដល់សេដ្ឋកិច្ចគ្រួសារនៃអ្នកទាំងនោះទៀតផង។

- ពន្ធនាគារកម្ពុជាភាគច្រើន តែងតែឃុំអ្នកទោសជាអនីតិជន លាយឡំចម្រុះគ្នាជាមួយអ្នកទោសពេញវ័យ។ ដែលនេះធ្វើអោយអនីតិជន អាចទទួលនូវការចែករំលែកអំពីការប្រព្រឹត្តបទល្មើសផ្សេៗ ពីមនុស្សពេញវ័យ។ ហេតុដូចនេះវិធីសាស្ត្រ ផ្តន្ទាទោសដោយមិនប្រើប្រាស់ប្រព័ន្ធពន្ធនាគារនេះ គឺជាផ្តល់នូវប្រយោជន៏យ៉ាងសំខាន់ក្នុងការបង្កា និងទប់ស្កាត់បទល្មើសនាពេលអនាគត។

វិធីផ្តន្ទាទោសដោយមិនប្រើប្រាស់ប្រព័ន្ធពន្ធនាគារ វាមិនអាចធ្វើបានភ្លាមៗនោះទេ ដោយហេតុថា ការងារនេះតម្រូវឱ្យមានការពិនិត្យ និងកែទម្រង់ប្រព័ន្ធយុត្តិធម៌ទាំងស្រុងជាមុនសិន ដែលកិច្ចការទាំងនេះ គឺទាមទារទាំងពេលវេលា និងការសម្រេចចិត្តពីភាគីដែលពាក់ព័ន្ធសំខាន់ៗទាំងឡាយ ដោយរាប់ចាប់តាំងពីអ្នករៀបចំគោលនយោបាយ រហូតដល់នគរបាលយុត្តិធម៌។ ការផ្លាស់ប្តូរសំខាន់ៗ ដែលនឹងអាចដំណើរការទៅកើតបាន លុះត្រាតែមានកិច្ចសហប្រតិបត្តិការរវាងតួអង្គសំខាន់ៗទាំងអស់នោះ។

វិធីដាក់ទណ្ឌកម្មផ្សេង ដូចជា ការងារសហគមន៏ និងការផ្តន្ទាទោសដោយការព្យួរទោសជាដើម តម្រូវឱ្យមានបុគ្គលិក និងហេដ្ឋារចនាសម្ព័ន្ធដើម្បីត្រួតពិនិត្យ និងតាមដានទណ្ឌិតទាំងនោះដើម្បីអោយប្រាកដថាលក្ខខណ្ឌទាំងឡាយនៃការផ្តន្ទាទោសដោយមិនប្រើប្រាស់ប្រព័ន្ធពន្ធនាគា ត្រូវបានយកមកអនុវត្តបានល្អប្រសើរ។ ចៅក្រម

ព្រះរាជអាជ្ញា និងមេធាវីការពារ អាចតម្រូវឱ្យមានការហ្វឹកហ្វឺនទៅតាមស្ថានភាពសមរម្យមួយដើម្បីអនុវត្តវិធីសាស្ត្រនៃការផ្តន្ទាទោសដោយមិនប្រើប្រាស់ប្រព័ន្ធពន្ធនាគារ។ វិធីសាស្ត្រនេះអាចនឹងទទួលជោគជ័យបាន លុះត្រាតែវាត្រូវបានកំណត់ជាការងារអាទិភាព និងមានមូលនិធិគ្រប់គ្រាន់សំរាប់ដំណើការ។

វិធីសាស្ត្រខាងលើនេះ គឺជាវិធីសាស្ត្រមួយដែលត្រូវចំណាយពេលខ្លីនៅពេលដំបូង ប៉ុន្តែវាបានជួយសន្សំ និងចំណេញវេលាជារបហូត ក្រោយវិធីសាស្ត្រខាងលើនេះ ត្រូវបានអនុវត្តន៍ពេញលេញ។ ការផ្តន្ទាទោសដោយមិនប្រើប្រាស់ប្រព័ន្ធពន្ធនាគារ គឺត្រូវចំណាយតិចជាងការឃុំឃាំងមនុស្សនៅក្នុងពន្ធនាគារ ដោយហេតុថា រដ្ឋាភិបាលមិនចាំបាច់ចំណាយលើកន្លែងឃុំឃាំង អគារឃុំឃាំង ម្ហូបអាហារ និងសម្លៀកបំពាក់ដល់អ្នកទោសទេ។ ដោយប្រព័ន្ធខាងលើនេះ គឺអ្នកទោសជាអ្នកចំណាយទាំងអស់ដោយខ្លួនឯង ស្របពេលដែលអ្នកទាំងនោះ ត្រូវបានអនុញ្ញាតឱ្យបំពេញមុខរបរទទួលទាននៅក្នុងសង្គមជាធម្មតា ក្រោមការត្រួតពិនិត្យយ៉ាងម៉ត់ចត់ក្នុងរយៈពេលណាមួយដោយអាជ្ញាធររដ្ឋ។

## អនុសាសន៍

លីកាដូ សូមផ្តល់អនុសាសន៍ដូចខាងក្រោម:

- រដ្ឋាភិបាលគួរធ្វើការវាយតម្លៃនូវ គោលនយោបាយយុត្តិធម៌ និងព្រហ្មទណ្ឌរបស់ខ្លួន ជាប្រព័ន្ធទទួលខុសត្រូវរួមមួយ ដើម្បីជៀសវាងក្រសួងមហាផ្ទៃ ដោយមានអគ្គនាយកដ្ឋានពន្ធនាគារ ធ្វើការដោះស្រាយនូវបញ្ហាខាងលើនេះម្នាក់ឯង។ ឧទាហរណ៍ ដូចជាបញ្ហាកំណើនអ្នកទោស បណ្តាលអោយមានការចង្អៀតណែននេះជាដើម។ ដើម្បីអោយមានភាពងាយស្រួលក្នុងការចូលរួមការទទួលខុសត្រូវ រាជរដ្ឋាភិបាលត្រូវធ្វើការប្រមែប្រមូល និងរៀបចំឡើងនូវព័ត៌មានសំខាន់ៗស្តីពីអ្នកទោស ដែលជាប់ឃុំនៅក្នុងពន្ធនាគារអោយបានត្រឹមត្រូវ និងអាចជឿទុកចិត្តបាន ក្នុងនោះរួមទាំងមានព័ត៌មានលំអិតមួយចំនួនផងដែរ ដូចជាថេរវេលាជាប់ទោស បទល្មើស និងអាយុ របស់អ្នកទោសជាដើម ដែលព័ត៌មានទាំងនេះ វានឹងជួយដល់ការសម្រេចចិត្ត ដែលទាក់ទងនឹងការអនុវត្តន៍គោលនយោបាយយុត្តិធម៌ និងព្រហ្មទណ្ឌ។

- ក្រសួងយុត្តិធម៌ និងមហាផ្ទៃ ព្រមទាំងស្ថាប័នពាក់ព័ន្ធនានា ត្រូវចាប់ផ្តើមពីមួយជំហ៊ានម្តងៗ ឆ្ពោះទៅរកការបង្កើតឡើងនូវហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានា ដើម្បីអនុវត្តនូវការផ្តន្ទាទោសដោយមិនប្រើប្រាស់ប្រព័ន្ធពន្ធនាគារក្នុងវិសាលភាពដ៏ធំទូលាយមួយ។ ជំហ៊ានទាំងនោះគួររួមមានការបណ្តុះបណ្តាលព្រះរាជអាជ្ញា បុគ្គលិកយុត្តិធម៌ទាំងឡាយ និងមេធាវីការពារក្តី អំពីការប្រើប្រាស់ឱ្យបានត្រឹមត្រូវ ការផ្តន្ទាទោសដោយមិនប្រើប្រាស់ប្រព័ន្ធពន្ធនាគារ និងជាមួយនឹងការបង្កើតឡើងនូវនាយកដ្ឋានសាកល្បង ឬ ការិយាល័យណាមួយរបស់រដ្ឋស្រដៀងនេះ ដើម្បីធ្វើការត្រួតពិនិត្យ និងស្តារនីតិសម្បទាដល់អ្នកទោស។

- ក្រសួងយុត្តិធម៌គួរចាត់វិធានការភ្លាមៗ ដើម្បីអនុវត្តនូវការផ្តន្ទាទោសដោយមិនប្រើប្រាស់ប្រព័ន្ធពន្ធនាគារចំពោះជនជាប់ចោទណា ដែលមានស្ថានភាពសមស្របអាចឱ្យនៅក្រៅឃុំបាន ដោយផ្អែកលើការវិនិច្ឆ័យទោស។ ការវិនិច្ឆ័យនេះ អាចចាប់ផ្តើមជាមួយនឹងក្រុមការងារពិសេស ដើម្បីពិនិត្យមើលគ្រប់ករណីដែលត្រូវបានកាត់ទោសជាប់ពន្ធនាគារពី ៣ ឆ្នាំ ឬ តិចជាងនេះ ដែលជាច្រកមួយ ដែលអាចអនុវត្តទណ្ឌកម្ម ការងារសហគមន៍ ដូចមានកំណត់ក្នុងក្រមព្រហ្មទណ្ឌថ្មីនៃព្រះរាជាណាចក្រកម្ពុជា។

- ក្រសួងយុត្តិធម៌ និងតុលាការ គួរកាត់បន្ថយការឃុំខ្លួនមុនពេលជំនុំជំរះក្តី មានពិរុទ្ធជនជាង ៣.៨០០ នាក់ ដែលត្រូវបានជាប់ឃុំបណ្តោះអាសន្ន ដែលនេះជាបន្ទុកមួយយ៉ាងធ្ងន់សម្រាប់កិច្ចការពន្ធនាគារកម្ពុជា។ ការដោះលែងបណ្តោះអាសន្ន ឬការអោយនៅក្រៅឃុំ ចំពោះបទល្មើសកម្រិតស្រាល និងបទល្មើសមិនហិង្សា គួរអនុវត្តតាមគោលការណ៍ច្បាប់ជាធរមាន។

- ការផ្តន្ទាទោសដាក់ពន្ធនាគារគួរចាត់ទុកជាជម្រើសចុងក្រោយ ហើយពុំមែនជាជម្រើសដែលខុសសម្រាប់គ្រប់ករណីទាំងអស់ទេ ។

- ក្រសួងមហាផ្ទៃ គួរផ្តោតទៅលើគុណភាពប្រសើរជាជាងបរិមាណក្នុងការកសាងពន្ធនាគារ ។ ពន្ធនាគារកសាងថ្មីទាំងនេះច្រើនតែពុំទាន់មានលក្ខណៈគ្រប់គ្រាន់ តម្រូវឱ្យមានថវិកាដើម្បីកែលំអរពីក្រុមអ្នកផ្តល់ជំនួយអន្តរជាតិ ដើម្បីធ្វើឱ្យអគារទាំងឡាយអាចប្រើការបាន ។ ដោយសារតែមានការកែលំអរពន្ធនាគារនាពេលបច្ចុប្បន្ននេះមានការកើនឡើង ដូច្នេះការពឹងផ្អែកទាំងស្រុង តែលើជំនួយពីខាងក្រៅ គឺពុំមាននិរន្តភាពទេ ។

## ៣. មណ្ឌលអប់រំកែប្រែទី ៤ និង ការបណ្តុះបណ្តាលវិជ្ជាជីវៈ

លីកាដូគាំទ្រចំពោះផែនការរបស់អគ្គនាយកដ្ឋានពន្ធនាគារក្នុងការផ្លាស់ប្តូរពី ពន្ធនាគារដាក់ទណ្ឌកម្មទៅជាពន្ធនាគារស្តារនីតិសម្បទាវិញ។ ការបណ្តុះបណ្តាលជំនាញ គឺជាផ្នែកមួយដ៏សំខាន់នៅក្នុងគ្រប់កិច្ចប្រឹងប្រែងស្តារនីតិសម្បទាទាំងអស់។ លើសពីនេះទៅទៀត ការបញ្ចេញអ្នកទោសក្រៅអាគាឃុំឃាំងដើម្បីធ្វើហត្ថកម្ម ពលកម្ម ឬបណ្តុះបណ្តាលនូវវិជ្ជាជីវៈ គឺជាតំរូវការយ៉ាងខ្លាំងនៃផ្នែកសុខភាពរបស់អ្នកទោស។



*អ្នកទោសក្នុងពន្ធនាគារខេត្តព្រះសីហនុ ចូលរួមក្នុងវគ្គបណ្តុះបណ្តាលជាជាងផ្សារដែក ក្រោមការជួយឧបត្ថម្ភពីមូលនិធិដុនប៊ូសស្កូ*

ទោះជាយ៉ាងណាក៏ដោយ កម្មវិធីស្តារនីតិសម្បទាទាំងនេះ អាចដំណើការទៅដោយជោគជ័យបាន គឺពឹងផ្អែកលើការរៀបចំគំរោងការងារលំអិត និងជាក់ច្បាស់។ ដោយហេតុថា ការទទួលព័ត៌មានអំពីគំរោងស្តារនីតិ-សម្បទានេះ នៅមានក៏រិតនៅឡើយ លីកាដូមានការព្រួយបារម្ភអំពីការប្រើប្រាស់កំលាំងពលកម្មអ្នកទោសនៅ ម៤ នេះ។

**តម្លាភាពៈ**

មកដល់ពេលនេះ គេបានដឹងតិចតួចបំផុតអំពីការរៀបចំលំអិតនៃកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងមណ្ឌលអប់រំកែប្រែទី៤នេះ ដោយសារតែគម្រោងស្ថិតនៅក្នុងដំណាក់កាលអភិវឌ្ឍន៏ដំបូងរបស់ខ្លួន។ ប៉ុន្តែនៅពេលដែលគម្រោងនេះ មានការរីកចំរើន លីកាដូ សុំស្នើឱ្យអគ្គនាយកដ្ឋានចាត់វិធានការជាជំហ៊ាន១ដើម្បីធានាឱ្យបាននូវ

តម្លាភាព និងប្រសិទ្ធិភាពរបស់កម្មវិធីបណ្ដុះបណ្ដាល ដូចខាងក្រោមៈ

១-ផ្សព្វផ្សាយរបាយការណ៏សាធារណៈឱ្យបានទៀងទាត់ស្ដីពីប្រភេទការងារដែលអ្នកទោសកំពុងធ្វើ។

២-ផ្សព្វផ្សាយឱ្យបានទៀងទាត់នូវរបាយការណ៏ហិរញ្ញវត្ថុរបស់កម្មវិធី ដោយរួមមានគណនេយ្យលំអិតស្ដីពី ចំណូល ចំណាយ និងចំណូលដែលត្រូវបានយកទៅវិនិយោគសារឡើងវិញ។

៣-ផ្សព្វផ្សាយនូវគណនេយ្យទៀងទាត់ ស្ដីអំពីការប្រើប្រាស់ផលិតផលម្ហូបអាហារ ឧទាហរណ៏ តើម្ហូបអាហារទាំងនោះត្រូវបានប្រើប្រាស់នៅតាមពន្ធនាគារកម្ពុជានានា ឬត្រូវបានលក់នៅឯផ្សារដើម្បីបានប្រាក់ចំណូល។

៤-ផ្សព្វផ្សាយបញ្ជីឈ្មោះអង្គការ ឬក្រុមហ៊ុនដៃគូរទាំងឡាយ ទាំងអ្នកទទួលធ្វើ/លក់បន្ត ឬអតិថិជន (ដោយមានព័តិមានលំអិតនៃការកិច្ចការវិនិយោគនៅក្នុងគម្រោងរបស់ដៃគូទាំងនោះផង) ប្រសិនបើមាន។

៥-ផ្សព្វផ្សាយជាផ្លូវការ នូវគោលនយោបាយទាំងឡាយ ស្ដីអំពីតំលៃពលកម្មដែលអ្នកទោសនឹងទទួលបានពីការងារដែលខ្លួនធ្វើ ហើយអនុវត្តប្រព័ន្ធមួយដើម្បីកត់ត្រាលំអិត អំពីការបើកប្រាក់ឱ្យអ្នកទោស និងម៉ោងធ្វើការងារ។

៦-អនុញ្ញាតឱ្យអង្គការមិនមែនរដ្ឋាភិបាល និងអង្គការឃ្លាំមើលអំពីស្ថានភាពពលកម្ម ធ្វើការពិនិត្យអំពីស្ថានភាពការងាររបស់អ្នកទោស។

៧-អនុម័តនូវយន្តការគ្រប់គ្រងលំអិតរួមគ្នា ដើម្បីគ្រប់គ្រងកម្មវិធីរួមមាន វិធាននានាដើម្បីធានាឱ្យបាននូវការអនុវត្តន៏ជំហ៊ានខាងលើ[៣៣]។

## ការប្រើពលកម្មអ្នកទោស ជាប្រយោជន៏ឯកជន

យោងតាមសារព័តិមានក្នុងស្រុកបានអោយដឹងថា ដំណាំកៅស៊ូ និងអំពៅ ត្រូវបានចាប់ផ្ដើមដាំនៅមណ្ឌលអប់រំកែប្រែទី៤[៣៤]។ ប្រភពពីមន្ត្រីរដ្ឋាភិបាលបានអោយលីកាដូដឹងថា រដ្ឋាភិបាលកំពុងពិនិត្យមើលលទ្ធភាពក្នុងការពង្រីកមណ្ឌលអប់រំកែប្រែទី៤ លើការដាំដំណាំកៅស៊ូ។ អគ្គនាយកដ្ឋានពន្ធនាគារក៏បានបង្ហាញផងដែរថា កាលពីឆ្នាំ២០០៨ កន្លងទៅនេះ ខ្លួនចង់ "ស្វែងរកដៃគូរវិនិយោគជាតិ ឬអន្តរជាតិដើម្បីជួយក្នុងគម្រោងអភិវឌ្ឍន៏

[៣៣] អគ្គនាយកដ្ឋានពន្ធនាគារបានសន្យាកាលពីឆ្នាំ២០០៨ ថានឹង" បង្កើតឱ្យមាននូវយន្តការគ្រប់គ្រងហិរញ្ញវត្ថុមួយប្រកបដោយការទទួលខុសត្រូវ និងតម្លាភាព ព្រមទាំងបង្កើតនូវនីតិវិធី និងបទបញ្ជាផ្ទៃក្នុងដើម្បីគ្រប់គ្រងចំណូលដែលបានមកពីឧស្សាហកម្ម/កសិកម្មពន្ធនាគារ ព្រមទាំងដើម្បីគ្រប់គ្រងលក្ខខណ្ឌជ្រើសរើសសម្រាប់អ្នកទោស។ "សូមអានរបាយការណ៏ប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋានពន្ធនាគារឆ្នាំ២០០៧ ទំព័រទី៨។ ប៉ុន្តែ លើសពីអ្វីដែលមន្ត្រីពន្ធនាគារបានរៀបរាប់អំពីការបែងចែកចំណូល ២០% សម្រាប់បើកប្រាក់ឈ្នួលឱ្យអ្នកទោស។ លីកាដូ ពុំទាន់ឃើញមានភស្តុតាងតម្លាភាពណាមួយឱ្យបានរឹងមាំនៅក្នុងកម្មវិធីនេះនៅឡើយទេ។ ផ្ទុយទៅវិញ នាយកពន្ធនាគារមើលទៅហាក់ដូចលាក់ការសម្ងាត់បន្តិចអំពីដៃគូរឯកជនរបស់កម្មវិធី ហើយលីកាដូបានទទួលរបាយការណ៏យ៉ាងទៀតទាត់ ពាក់ព័ន្ធនឹងអ្នកទោសមួយចំនួន មិនបានទទួលប្រាក់ឈ្នួល ឬ បានទទួលប្រាក់ឈ្នួលតិចតួចប្រហែលជា ២-៣ ដុល្លាអាមេរិក ប៉ុណ្ណោះក្នុង ១ខែ។

[៣៤] សូមអានកាសែតភ្នំពេញប៉ុស្តិ៍ ដែលមានចំណងជើងថា" *ឆ្នាំគុករារាំងការរត់គេចរបស់អ្នកទោស*" និពន្ធដោយម៉ៃ ទិត្ថារ៉ា ថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១០ ទំព័រទី៣

ឧស្សាហកម្ម និងកសិកម្មពន្ធនាគារនេះ"[៣៥] ។ អាស្រ័យតម្រូវការជំនាញ ទាំងការដាំដុះកៅស៊ូ និងដំណើរការផ្សេងៗនៃចង្វាក់ផលិតកម្មនេះ។ លីកាដូ មានការព្រួយបារម្ភលើអាជីវកម្មបែបនេះ ប្រហែលជាត្រូវការជំនួយពីសំណាក់នីតិបុគ្គលឯកជនណាមួយមិនខានឡើយ ហើយឧស្សាហកម្មដំណាំអំពៅនឹងត្រូវបានពិនិត្យឃើញនូវលទ្ធភាពដូចគ្នា។

ច្បាប់កម្ពុជាបានចែងយ៉ាងជាក់លាក់ អំពីការហាមឃាត់មិនឱ្យប្រើប្រាស់ពលកម្មពន្ធនាគារដើម្បីប្រយោជន៍ឯកជនឡើយ[៣៦] ។ ចំណែកឯច្បាប់អន្តរជាតិ វិញ ជាពិសេសអនុសញ្ញាអន្តរជាតិលេខ ២៩ បានចែងនូវការហាមឃាត់ដូចគ្នានេះដែរ[៣៧] តែទោះយ៉ាងណា ក៏នៅមានករណីលើកលែងផងដែរ តែវាត្រូវបានកំណត់ន័យយ៉ាងចង្អៀតបំផុត។ ច្បាប់ការងារកម្ពុជាក៏បានដាក់បញ្ចូលនូវអនុសញ្ញារបស់អង្គការពលម្មអន្តរជាតិលេខ ២៩ ជាច្បាប់របស់ប្រទេសនេះដែរ[៣៨] ។


ពលកម្មអ្នកទោសកំពុងត្រូវបានប្រើប្រាស់ក្នុងការសាងសង់ពន្ធនាគារ ម៤

លើសពីនេះទៅទៀត ប្រទេសមួយចំនួនដូចជា សហរដ្ឋអាមេរិក បានធ្វើការហាមឃាត់មិនឱ្យនាំចូលនូវផលិតផលទំនិញណា ដែលផលិតឡើងដោយពលកម្មអ្នកទោសទេ[៣៩] ។ អគ្គនាយកដ្ឋានគួរតែពិចារណាអំពីផលប៉ះពាល់នៃការអនុវត្តន៏កម្មវិធីបណ្តុះបណ្តាល ដែលអាចជាការប្រកួតប្រជែងជាមួយឧស្សាហកម្មឯកជន ដែលកំពុងតែរងគ្រោះដោយវិបត្តិសេដ្ឋកិច្ចពិភពលោកស្រាប់ផងនោះ។

លីកាដូ មានសំណូមពរដល់រដ្ឋាភិបាល ដើម្បីធ្វើការធានាថានឹងមិនឱ្យមានការកេងប្រវ័ញ្ចពលកម្មអ្នកទោសដើម្បីជាប្រយោជន៏ឯកជនឡើយ ទោះជានៅមណ្ឌលអប់រំកែប្រែទី៤ ឬ នៅពន្ធនាគារណាមួយនៅកម្ពុជា។ អគ្គនាយកដ្ឋានពន្ធនាគារត្រូវធានាឱ្យបានថា គ្រប់កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈទាំងអស់នៅក្នុងមណ្ឌលកែប្រែទី៤

---

[៣៥] របាយការណ៍ប្រចាំឆ្នាំ២០០៧ របស់អគ្គនាយកដ្ឋានពន្ធនាគារ អំពីសេចក្តីព្រាងក្របខណ្ឌគោលនយោបាយសម្រាប់កំណែទម្រង់ពន្ធនាគារ ទំព័រទី៥

[៣៦] បទបញ្ជារបស់អគ្គនាយកដ្ឋានបានចែងថា អ្នកទោស "មិនត្រូវបានបញ្ជាឱ្យធ្វើការណាមួយដែលបំរើផលប្រយោជន៏ឯកជនឡើយ។" សូមអាន នីតិវិធីពន្ធនាគារលេខ ១១ ភាគ ៣ និង ៤ (ចេញផ្សាយថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៣)។

[៣៧] អនុសញ្ញាអន្តរជាតិលេខ ២៩ ស្តីពីការងារដោយបង្ខំអនុម័តនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៣០ ដោយអង្គការពលកម្មអន្តរជាតិ ហើយត្រូវ បានផ្តល់សច្ចាប័នដោយរាជរដ្ឋាភិបាលកម្ពុជា នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៦៩។ សូមអានមាត្រា ២ (គ) អនុសញ្ញាមិនហាមឃាត់ " នូវការ ងារ ឬ សេវាកម្មណាដែលកេងយកចំណេញពីមនុស្សណា ជាផលវិបាកនៃការផ្តន្ទាទោសតាមច្បាប់តុលាការចែងថា ... មនុស្សនោះមិន ត្រូវបានជួលឱ្យ ឬ យកទៅបំរើបុគ្គលឯកជន ឬ ក្រុម ហ៊ុន ឬ សមាគមន៏ណាមួយឡើយ) ចំណែកឯមាត្រា ៤ (រដ្ឋាភិបាល មិនត្រូវបង្ខំ ឬ អនុញ្ញាតឱ្យមានពលកម្មដោយបង្ខំដើម្បីផលប្រយោជន៏បុគ្គលឯកជនណាម្នាក់ ឬ ក្រុមហ៊ុន ឬ សមាគមណាមួយឡើយ) ហើយមាត្រា ៥ (គ្មានសម្បទានណាមួយដែលផ្តល់ឱ្យបុគ្គល ឬ ក្រុមហ៊ុន ឬ សមាគមណាមួយអាចជាប់ពាក់ព័ន្ធក្នុងទម្រង់ពលកម្ម ដោយបង្ខំណាមួយក្នុង វិស័យផលិតកម្ម ឬ ប្រមូលផល ដែលបុគ្គលឯកជន ក្រុមហ៊ុន ឬ សមាគមនោះ ប្រើប្រាស់ ឬ ធ្វើពាណិជ្ជកម្មឡើយ)។

[៣៨] មាត្រា ១៥ នៃច្បាប់ការងារនៃព្រះរាជាណាចក្រកម្ពុជា។

[៣៩] ច្បាប់ពន្ធដាអាមេរិក ឆ្នាំ១៩៣០ ភាគទី ៣០៧។

ត្រូវបានប្រព្រឹត្តទៅក្រោមការត្រួតពិនិត្យជាសាធារណៈ និងដើម្បីបម្រើផលប្រយោជន៍រួម ។

## ប្រាក់ឈ្នួលអ្នកទោស

កាលពីខែកុម្ភៈកន្លងទៅ លីកាដូបានទទួលដំណឹងថា អ្នកទោសនៅមណ្ឌលអប់រំកែប្រែទី ៤ បច្ចុប្បន្នមិនទាន់បានទទួលប្រាក់ឈ្នួលការងារនៅឡើយទេ ពីព្រោះកម្មវិធីកសិកម្មនៅមិនទាន់មានចំណូលនៅឡើយទេ។ ជាការជំនួសឱ្យប្រាក់ឈ្នួល ប្រភពពីមណ្ឌលអប់រំកែប្រែទី៤ បានបញ្ជាក់ថា អគ្គនាយកដ្ឋានអាចលើកជាសំណើរទៅក្រសួងយុត្តិធម៌ សុំឱ្យមានការបន្ធូរបន្ថយទោស ដល់អ្នកទោសដើម្បីជាថ្នូរនឹងការជួយកសាងមណ្ឌលនេះ។

លីកាដូ មានសំណូមពរឱ្យក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ សហការគ្នាលើបញ្ហានេះ។ តាមអ្វីដែលគេចង់បាន គឺថាផែនការនេះគួរតែកំណត់ឱ្យបានជាក់លាក់ នូវកម្រិតទោសដែលត្រូវបន្ធូរបន្ថយជាថ្នូរនឹងពេលវេលាធ្វើការងារ ឧទាហរណ៍ ធ្វើការបាន ១ សប្តាហ៍អាចបន្ថយទោសបាន ១ ថ្ងៃ ឬយ៉ាងណា?? ។

លីកាដូ ក៏សំណូមពរឱ្យអគ្គនាយកដ្ឋានពន្ធនាគារ អនុវត្ត និងចេញផ្សាយនូវគោលនយោបាយ ផ្តល់ប្រាក់ឈ្នួលដល់អ្នកទោស ឱ្យបានកាន់តែឆាប់កាន់តែល្អ ធ្វើដូច្នេះដើម្បីឱ្យអ្នកទោសបានទទួលនូវប្រាក់ឈ្នួលសមរម្យ និងត្រឹមត្រូវនៅពេលដែលកសិដ្ឋានពន្ធនាគារ ចាប់ផ្តើមផលិតចេញជាផលិតផលដែលមានចំណូល។

## ការជ្រើសរើសកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈសមរម្យ

ជាចុងក្រោយ លីកាដូ មានការព្រួយបារម្ភថា កសិកម្ម គឺជាកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈតែមួយគត់ដែលមាននៅមណ្ឌលអប់រំកែប្រែទី៤ នេះ។

តាមការប៉ាន់ប្រមាណ បានអោយដឹងថាប្រជាពលរដ្ឋកម្ពុជាប្រមាណ៨០% គឺជាកសិករ[៤០] ។ កត្តានេះនាំឱ្យមានបញ្ហាពីរ នៅពេលដែលនិយាយអំពីការបណ្តុះបណ្តាលអ្នកទោសក្នុងវិស័យកសិកម្ម។ ម្យ៉ាងអាចនិយាយបានថា មានអ្នកទោស៨០% អាចមានជំនាញខាងកសិកម្មរួចទៅហើយ ដូច្នេះការបណ្តុះបណ្តាលអាចត្រួតគ្នា ជាមួយជំនាញដែលពួកគេធ្លាប់មានស្រាប់។ ផ្នែកខ្លះក្នុងវិស័យកសិកម្ម ត្រឹមតែមានជំនាញសមល្មមក៏អាចប្រើការបាន។ ប្រសិនបើកម្មវិធី មានបំណងចង់កេងប្រវ័ញ្ច ពីប្រភពពលកម្មថោកៗរបស់អ្នកទោសដើម្បីរកចំណូលជួយពន្ធនាគារ នោះអ្នកទោសនឹងមិនបានទទួលអ្វីឱ្យប្រសើរជាងនេះដើម្បីជួយខ្លួនគេទេ នៅពេលពួកគេត្រូវបានដោះលែង។ ម្យ៉ាងវិញទៀត ប្រសិនបើកម្មវិធីនេះពិតប្រាកដតាមបេសកកម្មរបស់ខ្លួន កម្មវិធីត្រូវតែប្រឹងប្រែងបង្រៀនអ្នកទោសអំពី

---

[៤០] សូមមើលគេហទំព័រ "Deutsche –Welle Online " កម្ពុជាពឹងផ្អែកលើវិស័យកសិកម្មយ៉ាងខ្លាំង " ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១០ នៅក្នុងគេហទំព័រ: http://www2.dw-world.de/southasia/SoutheastAsia/1.236014.lhtml

ជំនាញកសិកម្មថ្មីៗ ដែលពួកគេអាចយកទៅប្រើប្រាស់នៅក្នុងស្រែចម្ការ នៅក្រោយពេលត្រូវដោះលែងឱ្យមានសេរីភាពវិញ។

ចុងបញ្ចប់ ទោះបីជាកម្មវិធីកសិកម្មនេះត្រូវបានគ្រប់គ្រងដោយជំនាញក៏ដោយ នោះគេគួរតែផ្តល់ជម្រើសឱ្យអ្នកទោស។ តាមមើលទៅកម្មវិធីនេះ ដូចជាមិនទំនងអាចផ្តល់អ្វីច្រើនដល់អ្នកទោសណា ដែលចង់ប្រកបមុខរបរនៅទីក្រុងទេ នៅក្រោយពេលដែលពួកគេត្រូវបានដោះលែង។ អគ្គនាយកដ្ឋានពន្ធនាគារគួរតែបើកកម្មវិធីឱ្យបានទូលំទូលាយជាងនេះបន្តិច ដែលអាចបណ្តុះបណ្តាលនូវជំនាញចម្រុះ។

គេសង្កេតឃើញមានសញ្ញាវិជ្ជមានមួយចំនួនពីខាងដើមគឺ: អគ្គនាយកដ្ឋានបានបង្ហាញថា ខ្លួនមានបំណងក្នុងការបញ្ចូលកម្មវិធី "ទីផ្សារ" ទៅក្នុងកម្មវិធីកសិកម្មរបស់ខ្លួននៅក្នុងពន្ធនាគារទាំងអស់[៤១]។ កម្មវិធីបែបនេះ ជាការផ្តល់លទ្ធភាពដល់អ្នកទោស ក្នុងការហ្វឹកហ្វឺនវិស័យជាច្រើនផ្សេងៗគ្នារួមមាន: ហិរញ្ញវត្ថុ គណនេយ្យ មុខវិជ្ជាផ្សេងៗទៀត ដែលទាក់ទងជាមួយការងារពាណិជ្ជកម្ម ដូចជា ការទិញ និងការលក់ទំនិញ/ផលិតផល ក៏ដូចជាការលក់នៅលើទីផ្សារ។

លីកាដូ មានសំណូមពរដល់អគ្គនាយកដ្ឋានពន្ធនាគារ អនុវត្តតាមផែនការរបស់ខ្លួន ហើយធ្វើយ៉ាងណាធានាឱ្យកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈនៅមណ្ឌលអប់រំកែប្រែទី៤ ធ្វើឡើងដោយជៀសវាងការប្រើឱ្យអ្នកទោសធ្វើការងារតែនៅក្នុងចម្ការ ដោយគ្មានបានទទួលនូវការបណ្តុះបណ្តាលអ្វីធំដុំ ហើយបង្ខំអោយធ្វើការដោយពលកម្មសុទ្ធសាធ។

[៤១] សូមអាន អគ្គនាយកដ្ឋានពន្ធនាគារ "ប្រព័ន្ធគ្រប់គ្រងកែប្រែ" គំរូព្រាង ចេញផ្សាយ ខែកក្កដា ឆ្នាំ២០០៥ ទំព័រទី១២។

## ៤. ការប្រមូលផ្តុំអ្នកទោស ទៅមណ្ឌលអប់រំកែប្រែថ្នាក់ជាតិ

ដោយលីកាដូគាំទ្រនូវគោលការណ៍ដាក់នៅដាច់ពីគ្នារវាង ពិរុទ្ធជន និងទណ្ឌិត។ ប៉ុន្តែការបញ្ជូនអ្នកទោសថ្មីៗនេះ ទៅមណ្ឌលអប់រំកែប្រែថ្នាក់ជាតិពីតាមបណ្តាខេត្តឆ្ងាយៗ ពុំមែនជាវិធីល្អដើម្បីសម្រេចគោលដៅនេះទេ។

ប្រព័ន្ធពន្ធនាគារកម្ពុជានាពេលបច្ចុប្បន្ន មានការខ្វះខាតនូវថវិកាដើម្បីផ្តល់ឱ្យអ្នកទោសឱ្យបានសមរម្យ។ ដូចនេះ អ្នកទោសទាំងឡាយច្រើនតែពឹងផ្អែកទៅលើ គ្រួសារ សាច់ញាតិ មិត្តភក្តិ និងអង្គការនានា ជួយឧបត្ថម្ភម្ហូបអាហារ ថ្នាំពេទ្យ និងសម្ភារៈចាំបាច់មួយចំនួនទៀត[៤២]។ ការឃុំឃាំងអ្នកទោស ២,៥០០នាក់ នៅតំបន់ដាច់ស្រយាលមួយនៃខេត្តពោធិ៍សាត់ គឺជំនួយបន្ទាប់បន្សំខាងលើ ត្រូវបានកាត់ផ្តាច់ស្ទើតែទាំងស្រុង ដោយហេតុថា អ្នកទោសភាគច្រើននៅក្នុងមណ្ឌលនេះ ពុំមែនសុទ្ធតែមកពីខេត្តពោធិ៍សាត់ទាំងអស់នោះទេនេះមានន័យថាគ្រួសាររបស់ពួកគេត្រូវជួបឧបសគ្គយ៉ាងធំក្នុងការចំណាយលើមធ្យោបាយធ្វើដំណើរទៅកាន់ទីតាំងដាច់ស្រយាលមួយនេះ។



*នេះជាជម្រើសផ្លូវចុងក្រោយ ទៅកាន់ ម៤។ ស្ថានភាពនេះ ធ្វើឱ្យមានការលំបាកដល់គ្រួសារ និងមិត្តភក្តិទៅសួរសុខទុក្ខអ្នកទោស*

មណ្ឌលអប់រំកែប្រែទី៤ ស្ថិតនៅតំបន់ឆ្ងាយដែលត្រូវធ្វើដំណើរប្រហែល ១ម៉ោង៣០នាទី ពីទីរួមខេត្តពោធិ៍សាត់ ហើយត្រូវធ្វើដំណើរកាត់ព្រៃតាមផ្លូវដ៏លំបាកមួយ។ សម្រាប់គ្រួសារធម្មតា ដោយគ្រាន់តែចំណាយថវិកាធ្វើដំណើរទៅក្រុងពោធិ៍សាត់នេះ វាពិបាកណាស់ទៅហើយ លើសពីនេះនៅមានបន្ថែមការចំណាយលើការស្នាក់នៅ ការហូបចុក ព្រមទាំងសោហ៊ុយធ្វើដំណើរទៅមកមណ្ឌលអប់រំកែប្រែទី៤ ទៀតនោះ ប្រាកដណាស់គ្រួសារអ្នកទោសភាគច្រើនស្ទើរតែគ្មានលទ្ធភាពដើម្បីឆ្លើយតបនូវតំរូវការនេះ។

ការពុំមានគ្រួសារចូលមកសួរសុខទុក្ខវាអាចប៉ះពាល់ជាភាពអវិជ្ជមានទៅលើលទ្ធភាពរបស់អ្នកទោសក្នុងការវិលត្រឡប់ចូលទៅរស់នៅក្នុងសហគមន៍វិញក្រោយពេលដោះលែង ដែលនេះ គឺជាការដើរបញ្ច្រាសទិសគ្នានូវគោលដៅមួយរបស់អគ្គនាយកដ្ឋានពន្ធនាគារ ដែលបានលើកឡើងថា ផ្លាស់ប្តូរឆ្ពោះទៅរកប្រព័ន្ធពន្ធនាគារដែលមានលក្ខណៈស្តារនីតិសម្បទាអ្នកទោសឡើងវិញ។ នៅក្នុងខែមិថុនា ឆ្នាំ២០១០ កន្លងទៅនេះ មានការប៉ុនប៉ងរត់គេច

[៤២] សូមមើលជាទូទៅ: របាយការណ៍អង្គការលីកាដូ: ស្ថានភាពពន្ធនាគារនៅកម្ពុជា ២០០៥- ២០០៦ និងរបាយការណ៍លីកាដូ: ស្ថានភាព ពន្ធនាគារ ឆ្នាំ២០០៤ (រៀបរាប់អំពីកង្វះខាតម្ហូបអាហារ ទឹក និងការថែទាំសុខភាព ព្រមទាំងមានអំពើពុករលួយក្នុងចំណោមបុគ្គលិក ដែលតែងតែទារលុយពីសាច់ញាតិអ្នកទោសចូលទៅសួរសុខទុក្ខ)។

ចំនួនពីរដងពីមណ្ឌលអប់រំកែប្រែទី៤ ដោយក្នុងនោះមានអ្នកទោសរហូតដល់ ១០នាក់ ដែលពាក់ពន្ធ័និងការរត់គេចខ្លួននេះ[៤៣] ។

ជាចុងក្រោយ លីកាដូមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះ ផែនការរបស់អគ្គនាយកដ្ឋានពន្ធនាគារ ដែលគ្រោងកសាងអគារពន្ធនាគារមួយខ្នងសម្រាប់ដាក់អ្នកទោសជាអនីតិជន ៥០០នាក់ ។ ដោយរហូតមកដល់ខែឧសភា ឆ្នាំ២០១០ នេះ ចំនួនទណ្ឌិតអនីតិជនជាបុរសមានរហូតដល់ ៥៣៨នាក់ នៅក្នុងពន្ធនាគារដែលលីកាដូឃ្លាំមើល ។ ដូច្នេះ ពេលណាមួយអ្នកទោសអនីតិជន ទាំងនេះនឹងត្រូវបញ្ជូនទៅមណ្ឌលអប់រំកែប្រែទី៤ ជាមិនខានដើម្បីបំពេញអគារដែលនៅទំនេរ ។

ទំនាក់ទំនងគ្រួសារ គឺជាកត្តាសំខាន់សម្រាប់ការស្តារនីតិសម្បទា នៃអ្នកទោសជាអនីតិជនទាំងនោះ ។ ដូច្នេះ រដ្ឋាភិបាលគួរតែខិតខំប្រឹងប្រែងទ្វេរដង ដើម្បីអនុម័តនូវច្បាប់ស្តីពីយុត្តិធមិកុមារ មួយប្រកបដោយប្រសិទ្ធិភាពដែលភាគច្រើនផ្តោតទៅលើការប្រើប្រាស់វិធីសាស្ត្រផ្សេងៗ និងវិធានការឥតឃុំឃាំង ។ នៅក្នុងឃ្លាំងសម្រាប់ដាក់ជនល្មើសយុវជន គ្មានអ្វីក្រៅពីបាត់បង់នូវឱកាសដើម្បីធ្វើសមាហរណកម្មឱ្យបានជោគជ័យទេ ។

### អនុសាសន៍ ដើម្បីដោះស្រាយនូវបញ្ហាខាងលើ

- អគ្គនាយកដ្ឋានពន្ធនាគារគួរពិចារណាអំពីខេត្តរបស់អ្នកទោស នៅពេលដែលត្រូវបញ្ជូនទៅមណ្ឌលអប់រំកែប្រែទី៤ ជាដំបូងមណ្ឌលនេះ គួរដាក់តែអ្នកទោសក្នុងខេត្តពោធិ៍សាត់ និងខេត្តនៅជិតៗនោះបានហើយ ។
- អគ្គនាយកដ្ឋានពន្ធនាគារគួរផ្តោតទៅលើការរៀបចំផ្លូវឆ្ពោះទៅកាន់មណ្ឌលអប់រំកែប្រែទី៤នេះ ឱ្យបានសមរម្យ ដោយស្ថានភាពផ្លូវបច្ចុប្បន្នពិបាកធ្វើដំណើរខ្លាំងណាស់ ។ ជាពិសេស គឺកំណាត់ចុងផ្លូវ (នៅពេលជិតទៅដល់មណ្ឌល) ប្រហែល ១០គីឡូម៉ែត្រ ហើយនៅរដូវវស្សាស្ទើរតែមិនអាចធ្វើដំណើរទៅរួចតែម្តង ។
- អ្វីដែលសំខាន់ជាងគេបំផុតនោះគឺ ក្រសួងមហាផ្ទៃ គួរធ្វើការពិចារណា ពិនិត្យឡើងវិញ លើគម្រោងនៃការឃុំឃាំងអ្នកទោស២,៥០០ នាក់ នៅមណ្ឌលអប់រំកែប្រែទី៤ នេះ ។ ដោយហេតុថាចំនួន អ្នកទោសទាំងអស់នេះ គឺស្ទើរតែស្មើ ២០% នៃអ្នកទោសកម្ពុជាបច្ចុប្បន្នសរុបទៅហើយ និងស្ទើរតែ ៣០% នៃទណ្ឌិតកម្ពុជាសរុប ។ ថវិកាដែលប្រើប្រាស់សម្រាប់កសាងមណ្ឌលអប់រំកែប្រែ ទី៤ អាចគួរត្រូវបានប្រើប្រាស់ដើម្បីកសាងពន្ធនាគារតូចៗនៅក្នុងខេត្ត ដែលជាទីតាំងងាយស្រួលសម្រាប់គ្រួសារទៅ សួរសុខទុក្ខ ដោយទាំងនេះ គឺជាការកាត់បន្ថយចំណាយរបស់ពួកគេ សំរាប់ការសាកសួរសុខទុក្ខម្តងៗ ។ ម្យ៉ាង វិញទៀត គួរបង្វែរថវិកាទាំងនោះទៅប្រើប្រាស់ក្នុងការអនុវត្តន៍ ការផ្តន្ទាទោសដោយមិនប្រើប្រាស់ប្រព័ន្ធ ពន្ធនាគារ ជាពិសេសចំពោះទណ្ឌិតជាអនីតិជន ។

---

[៤៣] សូមអានកាសែតភ្នំពេញប៉ុស្តិ៍ ដែលមានចំណងជើងថា "*ឆ្នាំគុករារាំងការរត់គេចរបស់អ្នកទោស*" និពន្ធដោយ ម៉ៃ ទិត្ថារ៉ា និងមុំ គន្ធា ថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១០ ទំព័រទី៣